សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធនា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

# ពិធីបុណ្យអុំទូកនៅឡូវែល

## 21st Annual Lowell Southeast Asian Water Festival 2017

**ដោយ ពិន សំខុន**

**ឡូវែល:** មនុស្សម្នាប្រមាណ៣ម៉ឺននាក់ បាននាំគ្នាមកទីគ្រប់ទិសទីនៃតំបន់"ញូអនគ្លិន" ចូលរួមពិធីបុណ្យអុំទូកនៅឡូវែល កាលពីថ្ងៃទី១៩ កក្កដា២០១៧ ក្រោមបរិយាកាសជាគ្រួសារអាស៊ី នឹងក្រោមធាតុអាកាសថ្ងៃក្ដៅលើស៨០អង្សា ។ ដូចរៀងរាល់ឆ្នាំ ការប្រណាំងទូកជាប្រពៃណីរបស់ប្រជាពលរដ្ឋខ្មែរ ជាអតីតមហានគរ ដែលបានលាតត្រដាងឥទ្ធិពលរបស់ប្រទេសនៅលើតំបន់មានវិសាលភាពធំធេង តាំងពីសតវត្សទី១រហូតដល់សតវត្សទី១៤ បានត្រូវយកមកប្រារព្ធជារៀងរាល់ឆ្នាំនៅថ្ងៃសៅរ៍ នៃសប្ដាហ៍ទី៣នាខែកក្កដា នៅទន្លេ"មេរីម៉ាក"ត្រង់កន្លែងទំនប់ទឹកធ្លាក់សិប្បនិមិត្ត ដែលកសាងឡើងកាលពី១០០ឆ្នាំមុន

តទៅទំព័រទី១០



អុំទូកផ្ដាច់ព្រ័ត្ររវាងនារីក្លាហាន និងបុរស

# ពិពណ៌ចម្រុះវប្បធម៌ឆ្នាំ២០១៧នៅឡូវែល

## Lowell Folk Festival 2017

**ដោយ ពិន សំខុន**

**ឡូវែល–** មនុស្សច្រើនពាន់នាក់ បានប្រជ្រៀតចូលក្រុងឡូវែលតាំងពីល្ងាចថ្ងៃសុក្រទី២៨កក្កដា មកស្ដាប់ភ្លេងនៃក្រុមតន្ត្រីល្បីៗច្រើនក្រុមនឹងច្រៀងរាំតាមថ្នល់នាកណ្ដាលក្រុងជុំវិញសាលាក្រុង



សូបិន្ត និងអាល់ ជាពិធីករនៅទូរទស្សន៍ “LTC”

ដែលម្ដុំផ្លូវ"មេរីម៉ាក់-ម៉ាកេតស្ទ្រីត-ផ្លូវដុតុន" បានត្រូវបិទដោយអន្លើដោយសារក្រុងឡូវែលប្រារព្ធពិធីបុណ្យប្រចាំឆ្នាំរបស់ខ្លួនឈ្មោះ "ឡូហ្វកហ្វេសទីវល"។ ក្នុងរយៈពេលចំនួន៣ថ្ងៃ៣យប់បន្តបន្ទាប់ គឺថ្ងៃសៅរ៍ ទី២៩ នឹងថ្ងៃអាទិត្យទី៣០ មិថុនា ឡូវែលនៅតែទាក់តាញមនុស្សម្នា

តទៅទំព័រទី ០៤

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ


978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

KhmerPost USA
Cambodian American Biweekly Newspaper
Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS
Contact us for the Advertising Opportunity!
978-677-7163 | http:/khmerpost.us

# សម្ភាសន៍លោក ជន លីហ៊ី ជាសមាជិកគណកម្មការ សាលាក្រុងសិក្សាបណ្តឹងរបស់ក្រុមភាគតិច

**ដោយ សូបិន ពិន**

លោក ជន លីហ៊ី សមាជិកក្រុមប្រឹក្សាក្រុងឡូវែលបានផ្តល់បទសម្ភាសន៍ដល់ខ្មែរផុសស.រ.អា. ស្តីអំពីបណ្តឹងចំពោះសាលាក្រុងឡូវែលពីបទ "រំលោភសិទ្ធធម្មនុញ្ញរបស់ក្រុមជនជាតិភាគតិច" កាលពីថ្ងៃអាទិត្យទី១១។ កន្លងទៅនៅ "ប៊ូតម្យៀល"។ ចំពោះរឿងនេះ លោកអភិបាលក្រុង អេដ កេណ្ណឺឌី បានចាត់តំណាងរបស់លោក គឺលោក ជីម ឡេរី នឹងសមាជិក២រូបទៀត ឱ្យសិក្សាករណីបណ្តឹងនេះ ហើយធ្វើការស្នើរយោបល់ត្រឡប់មកសាលាក្រុងវិញ នៅខែកញ្ញា។ ផ្ទុយនឹងជំហ៊ារលោក វ៉តនី អេលីយ៉ុត ដែលកាលពីសប្តាហ៍មុនបង្ហាញជំហ៊ារការពារជនភាគតិច, រីឯលោក ជនលីហ៊ី មានទស្សនៈនៅផ្ទុយគ្នាដាច់ស្រឡះ។ សូមស្តាប់បទសម្ភាសន៍លោកជាមួយ សូបិន ពិន ដូចតទៅ:

**សូបិន ពិនៈ** ជម្រាបសួរលោកក្រុមប្រឹក្សា ! ខ្ញុំដឹងថា អនុគណកម្មការក្រុងបានជួបខាងក្រុមអ្នកប្តឹងសាលាក្រុងហើយ តើការជួបគ្នានេះបានដំណើរការយ៉ាងណាដែរ?

**ជន លីហ៊ីៈ** គណកម្មការយើងបានជួបគ្នានឹងមេធាវីដើមបណ្តឹង កាលពីថ្ងៃច័ន្ទកន្លងទៅរួចហើយ តែខ្ញុំពុំទាន់បានទទួលសេចក្តីរាយការពីកិច្ចប្រជុំនោះនៅឡើយទេ ខ្ញុំគ្រាន់តែដឹងថា នេះជាកិច្ចប្រជុំដំបូង ដើម្បីឱ្យដឹងថា "តើដើមបណ្តឹងគេចង់បានអ្វី?"



លោក ជន លីហ៊ី

**សូបិន ពិនៈ** តាមខ្ញុំដឹង ក្រុមជនភាគតិចគេយល់ថា "ប្រព័ន្ធបោះឆ្នោតនៅក្រុងឡូវែលសព្វថ្ងៃមិនយុត្តិធម៌ចំពោះពួកគេទេ!" មើលតំបន់ "បែលវើឌ្យ" មានដំណាងដល់ទៅ៦នាក់ រីឯសង្កាត់៥-៦ទៀត មានតំណាងតែ៣នាក់ប៉ុណ្ណោះ តើលោកយល់ថា "ពាក្យបណ្តឹងរបស់ពួកគេជនជាតិភាគតិចនោះ សមរម្យដែរឬទេ?"

**ជន លីហ៊ីៈ** ខ្ញុំមានការចូលចិត្តប្រព័ន្ធបោះឆ្នោតសព្វថ្ងៃនេះជាង ពីព្រោះដើម្បីឱ្យបានទៅកាន់ដំណែងជាដំណាងគេនៅសាលាក្រុង គឺម្នាក់ៗធ្វើការច្រើន ទៅជួបម្ចាស់ឆ្នោតស្ទើរគ្រប់គ្នា ជួបអ្នករកស៊ីជាពាណិជ្ជករ ជួបសមាគមគ្រប់សញ្ជាតិ ទម្រាំបានជាប់ឆ្នោត ហើយម្នាក់ៗតំណាងឱ្យឡូវែលទាំងមូលគិតពីផលប្រយោជន៍ឡូវែលដូចៗគ្នាម្ល៉ោះហើយធ្វើការចុះសម្រុងគ្នាបានល្អ ។ ប្រព័ន្ធសព្វថ្ងៃវាអាស្រ័យទៅលើអ្នកបោះឆ្នោតក្រុមជនភាគតិចមានការចូលរួមតិចនៅក្នុងនយោបាយ មិនចូលចិត្តទៅបោះឆ្នោត ដូច្នេះប្រាកដជាមានការលំបាកនឹងប្រកួតប្រជែង នោះគឺជារឿងធម្មតានៃការបោះឆ្នោត។ ប្រសិនបើមានការផ្លាស់ប្តូរប្រព័ន្ធយកតំណាងពីសង្កាត់និមួយៗទៅវិញ ម្នាក់ៗនឹងគិតតែពីផលប្រយោជន៍នៃសង្កាត់តែរៀងៗខ្លួន នឹងមានការប្រទាញប្រទង់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាក្រុង គឺមិនមែនជាការល្អដែលបង្ហាញពីការប្រេះឆាក្នុងសាលាក្រុងនោះទេ ...

**សូបិន ពិនៈ** មានប្រជាពលរដ្ឋជាច្រើននៃតំបន់ជនភាគតិចមិនហ៊ានប្រស្រ័យទាក់ទងទៅតំណាងនៅសាលាក្រុងទេ, តែបើមានតំណាងពីខាងជនជាតិភាគតិចជាសមាជិកទៅវិញ ការដោះស្រាយបញ្ហានៅសាលាក្រុងប្រហែលជាធ្វើទៅត្រូវនឹងការខ្វះខាតបានច្រើនជាង...

**ជន លីហ៊ីៈ** ខ្ញុំឃើញថា ពីខាងសហគមន៍ខ្មែរក៏ធ្លាប់មាន រីទ្ធី អ៊ុង បានជាប់ឆ្នោត២អាណត្តិ វ៉ាស្នា នួន ក៏ធ្លាប់ជាប់ឆ្នោត ឥឡូវមាន រ៉ាឌី ម៉ម ក៏បានជាប់ឆ្នោតចេញពីសហគមន៍ភាគតិចនេះ ក្នុងប្រព័ន្ធនេះបានដែរ... ខ្ញុំធ្លាប់ធ្វើការជាមួយ

**តទៅទំព័រទី ១៩**



# ព្រឹត្តិការប្លែកៗនៅសេដ្ឋវិមានប្រធានាធិបតី

**ដោយ ពិន សំខុន**

ចាប់តាំងពីលោកប្រធានាធិបតី ឌុណាល ត្រុម ចូលមកកាន់ការនៅសេដ្ឋវិមាន នារដ្ឋធានីវ៉ាស៊ីនតុនបាន២០០ថ្ងៃហើយ មានព្រឹត្តិការប្លែកៗបានកើតឡើងជាមួយនឹងទស្សនៈគ្រប់គ្រងជាច្រើន


ប្រធានាធិបតីកូរ៉េខាងជើង


ប្រធានាធិបតីអាមេរិក

ដែលមិនធ្លាប់មានពីមុនមក។

ព្រឹត្តិការណ៍ថ្មីបង្អស់នៃការប៉ះទង្គិចរវាងក្រុមជាតិនិយមស្បែកសជាមួយនឹងបាតុករនៅ "ឆាឡុត"កាលពីសប្តាហ៍មុនបណ្តាលឱ្យមានស្លាប់នឹងរបួសដោយបាតុករ"ស្បែកសជាតិនិយម"នោះ ឌុណាល ត្រុម បានត្រូវគេមើលឃើញថា នៅមិនឆ្ងាយពីក្រុមនោះទេ មិនតែប៉ុណ្ណោះ ក្រុម"ខេខេខេ" នឹងក្រុម"ណាហ្ស៊ី"ដែលប្រកាន់ពូជសាសន៍ ថែមទាំងកំពុងងើបឡើងទៀតផង។ នៅពេលដែលបាតុកម្មនៃសកម្មជនសិទ្ធមនុស្សនៅបន្តពី "ឆាឡុត" មកដល់រដ្ឋធានីវ៉ាស៊ីនតុននៅតែបន្តរហុទដល់ថ្ងៃពុធក្តី, ព្រឹត្តិការនេះរឹតតែធ្វើឱ្យប្រជាប្រិយភាពរបស់ប្រធានាធិបតីនៅពេល២០០ថ្ងៃនៃសេដ្ឋវិមានកាន់តែស្រុតថែមទៀត, អង្គការ "ហ្គាលុព" បានបញ្ចេញការស្ទង់មតិថា"ប្រជាប្រិយភាពបានចុះមកនៅត្រឹមតែ៣៤%ប៉ុណ្ណោះ ក្នុងចំណោមអ្នកដែលចូលចិត្ត ត្រុម។

សម្រាប់នយោបាយក្នុងប្រទេសអាមេរិកនាដើមសប្តាហ៍នៃខែសីហានេះ លោកប្រធានាធិបតី ឌុណាល ត្រុម កំពុងរវល់ជាមមាញឹកនឹងការប្រយុទ្ធប្រឆាំងបញ្ហាអន្តោប្រវេសន៍ ដែលលោកពិពណ៌នាថា "មិនឱ្យមានអន្តោប្រវេសន៍ដែលជនបរទេសចូលមកសម្រាប់តែមកស៊ីប្រាក់ជំនួយ ឬហៅថា វែលហ្វែនោះទេ..." ធ្វើយ៉ាងនេះ លោក ត្រុម មានមោទនភាពនឹងសន្សំថវិការបានច្រើនប៊ីលីយ៉ុនទៀតផង។ លោកនឹងចុះហត្ថលេខាលើបទបញ្ជាផ្សេងទៀត ដែលនឹងតម្រូវឱ្យជនអន្តោប្រវេសន៍ចេះនិយាយនឹងយល់ភាសាអង់គ្លេសតាំងតែពីដើមដំបូង នៅពេលដាក់ពាក្យសុំចូលមកសហរដ្ឋ, គេនៅមិនទាន់ដឹងពីវិធានការបន្តបន្ទាប់ រហូតដល់អាចប៉ះពាល់ដល់អ្វីខ្លះទៀត ដែលអ្នកមាន ឬក៏មិនទាន់ទទួលបាន"គ្រីនខត" នៅសហរដ្ឋនៅឡើយទេ តែវិធានការណ៏របៀបនេះ ទំនងជានឹងមានដំណើរទៅដល់ការរករឿងដល់អ្នកដែលដែលមកដល់ពីមុនៗនោះហើយ, ទាំងនេះជាផ្នែកនៃព្រឹត្តការចម្លែកថ្មីដែលគេសង្ស័យថា"នឹងមកដល់"នាអាណត្តប្រធានាធិបតីថ្មីនៅសហរដ្ឋអាមេរិកនេះ។

រឿងថ្មីៗដែលកំពុងផ្លាស់ប្តូរភ្លឹបភ្លែតនោះ លោក"ស្កាមូស៊ី" នាយកក្រសួងព័ត៌មាននៅសេដ្ឋវិមានថ្មីបានមកកាន់ដំណែងមិនទាន់បានមួយអាទិត្យផង ក៏ត្រូវបានត្រូវដកចេញពីដំណែងចំថ្ងៃដែលលោក"ជន កែលី" ដែលមកកាន់ការជំនួសដំណែងលោក"សេង ព្រីប៊ូស" ជានាយកខុទ្ទកាល័យប្រធានាធិបតី ក៏បានត្រូវលាចេញពីដំណែងក្នុងពេលស្ទើរតែជាមួយគ្នាបន្ទាប់ពីបានធ្វើការជូន ឌុណាល ត្រុម ៦ខែរួចមកហើយ។ មន្ត្រីអ្នកនាំពាក្យសេដ្ឋវិមានម្នាក់ឈ្មោះ "ស៊ិន ស្ប៉ាយស័រ" ទៀតបានក៏ត្រូវប្តូរផ្លាស់ ជំនួសដោយនាង "សារ៉ាហកាប៊ី"។ ការផ្លាស់ប្តូរនឹងរង្គោះរង្គើយ៉ាងរន្ថើននៃក្រុមអ្នកគ្រប់គ្រងនៅសេដ្ឋវិមាននេះ ក៏ព្រោះតែនយោបាយ ឌុណាល ត្រុម គឺជានយោបាយប្តូរ-ផ្លាស់ងាករេមិនមានគំរូពីមុនមកទេ។

នៅសេដ្ឋវិមាន មានការបង្កើតទស្សនៈប្លែកៗច្រើនដូចជា ការ "ប្រឆាំងនឹងព័ត៌មានក្លែងក្លាយ" របស់លោក ត្រុម ទៅនឹងការលើកឡើងរបស់អ្នកសារព័ត៌មានធំៗពីបញ្ហាជាតិនឹងពីអកប្បកិរិយារបស់ប្រធានាធិបតីរបស់គេ ហើយក៏មានរៀបចំ

**តទៅទំព័រទី ០៧**






តមកពីទំព័រទី ០១

# ពិពណ៌ចំរុះវប្បធម៌ឆ្នាំ២០១៧នៅឡូវែល

រហូតដល់ច្រើនម៉ឺននាក់ថែមទៀត ឱ្យមកទស្សនានឹងកំសាន្តកម្មវិធីដែលបានយកមកបង្ហាញរាប់រយមុខនាបរិវេណជុំវិញសាលាក្រុងយ៉ាងណែនណាន់តាន់តាប់នឹងយ៉ាងរីករាយ ។

សោភ័ណ្ឌភាពនៃរបស់របរដែលយកមកតាំងបង្ហាញពីលំអមានតាំងពីគំនូរចម្លាក់របស់សម្រាប់តាំងលំអក្នុងផ្ទះសម្បែង ឬនៅក្រៅផ្ទះ រហូតដល់តែងលំអលើខ្លួនប្រាណមានគ្រឿងអលង្កាជាដើម មានអ្នកចូលមើលនឹងសួរនាំមិនចេះខ្វិល, មានបង្ហាញបច្ចេកវិជ្ជានានាសម្រាប់យកមកប្រើជាប្រយោជន៍ដល់ពាណិជ្ជកម្មនឹងដល់គ្រួសារមានតាំងពីចរន្តអគ្គីសនីនាំបង្វិលគ្រឿងចក្រមានឧបករភ្លេងប្លែកៗ មានទាំងឋាមពលពន្លឺបង្កើតជាអគ្គីសនីបាន...។ល។, សិល្បៈសម្តែងជារបាំតាមថ្នល់លើឆាក ឬក្រុមភ្លេងល្បីឈ្មោះមកសម្តែងនៅឧទ្យាន ឬលើឆាកធំៗ ឬក៏សង់ជារោងសម្រាប់រាំកំសាន្តមានទាំងល្ខោនឆ្កិនភ្នែក ឬជាឆាកសម្តែងតុក្កតានោះគឺជាទីសំណប់ចិត្តរបស់ក្មេងៗនឹងមាតាបីតា, មានក្រុមជាងសិប្បកម្មច្រើនក្រុមមកបង្ហាញស្នាដៃកម្រមានឡទាំងអស់នោះ ហើយដែលធ្វើឱ្យបរិយាកាសរីករាយសម្រាប់គ្រប់រស់ជាតិសម្រាប់ក្មេង ឬយុវជន ឬក៏ចាស់មិនថា ជាស្រី ឬជាប្រុសឡើយ ។

សកម្មភាពដែលប្លែមមុនគេ នាវេលាថ្ងៃត្រង់ នៃថ្ងៃសៅរ៍ នឹងថ្ងៃអាទិត្យ គឺចំហាយនៃក្លិនភោជនាហារចម្រុះ ម្ហូបគ្រប់ជាតិសាសន៍ នឹងគ្រប់រស់ជាតិ តម្រៀបគ្នាជាជួរ នៅច្រើនកន្លែង តាមផ្លូវមីឌុញសិច ផ្លូវប្រាំង់ ទីធ្លាសាលាក្រុងទីធ្លាក្នុងវិហារកាតូលិកមុខសាលាក្រុង ផ្លូវម៉ាកិត ទីធ្លាធំល្វឹងល្វើយ នៃអាគារ"អិលទីស៊ី" មនុស្សរាប់រយនាក់តម្រៀបគ្នាជាជួរតាំងពីថ្ងៃត្រង់រហូតដល់យប់មិនដឹងជាកើបលុយបានច្រើនប៉ុណ្ណាទេ នាអំឡុងពិធីតែ៣ថ្ងៃនោះ។ ក្រុមឡាវមាន៣-៤កន្លែង









សកម្មខ្លាំងណាស់ នឹងមានមុខម្ហូបជាទីចូលចិត្តនៃសាធារណជន មានម្ហូបក្រិក ហ្វីលីពីន មានម្ហូបថៃ ម្ហូបភូមា មានម្ហូបស្បានីសច្រើនប្រទេស មានប្រទេសនីហ្សេរីយ៉ា មានប្រទេសអាហ្វ្រិកមួយចំនួនទៀត ។

ចម្រុះវប្បធម៌មែន ឬទេ? វប្បធម៌ដែលបាត់មុខគឺសហគមន៍ខ្មែរ ដែលក្រុងខ្មែរនៅក្បែរនេះសោះតែមិនមានបង្ហាញមុខនឹងគេនៅស្វាត់ឈឹងតែម្តង **តទៅទំព័រទី ០៨**


ដំណោះស្រាយការឱ្យខ្ចី
សម្រាប់លំនៅដ្ឋាន

កំពុងចង់ទិញផ្ទះថ្មីមួយនៅក្នុងរដ្ឋម៉ាស្សាជូសេត្ស៍, ញ៉ូហេមសឺរ ឬម៉េន ឬស្វែងយល់ពីអត្ថប្រយោជន៍នៃការបង់ប្រាក់ជាថ្មី? ពួកយើងជាអ្នកមានការដពិសោធន៍ ខាងនិក្ខេបនឹងជួយណែនាំ លោក-អ្នកឆ្លងកាត់ពីដំណាក់កាលដំបូងនៃការ ជ្រើសរើសហិរញ្ញវត្ថុ រហូតដល់ដំណាក់កាលចុងក្រោយនៃការទិញ។ ជាមួយនឹង ការសម្រេចដែលត្រូវធ្វើឡើង ជាមូលដ្ឋានយើងមានភាពបត់បែន និងឆ្លើយតប ហើយនិងអាចបង្កើត ដំណោះស្រាយ អោយបានលឿន និងមានប្រសិទ្ធិភាព។

មជ្ឈមណ្ឌលនិក្ខេបនៅ
នៅធនាគារអេនធ័រប្រាយស៍
978-656-5653 | 877-671-2265



យើងផ្តល់នូវកម្មវិធី និងសេវាកម្មជាច្រើនដើម្បីជួយលោក-អ្នក
ជាមួយតម្រូវការហិរញ្ញវត្ថុជាក់លាក់របស់អ្នក។

អនុវត្តនៅអនឡាញថ្ងៃនេះ!

Member FDIC

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com/Mortgage

# សិក្សាដោយមិនបង់ថ្លៃថ្នាក់មហាវិទ្យាល័យនៅ រ៉ូដអាយលិន

## Raimondo Signs FY 2018 Budget - State guarantees free community college for all

PROVIDENCE, R.I. - Governor Gina M. Raimondo signed the FY 2018 budget into law on August 3rd, 2017, and immediately following its passage by the Rhode Island State Senate.

"This is a Jobs Budget, with a lot in it to help Rhode Islanders," Raimondo said. "It makes Rhode Island the first state on the East Coast to make community college tuition-free for every high school graduate. It continues our record investments in classrooms across the state, increases the minimum wage and gives homecare and direct care workers a raise. And, it gives every Rhode Islander car tax relief. I will continue to do everything in my power to protect our progress, create more jobs, and give more Rhode Islanders the training and education they need to get the good jobs we're creating."

**ដោយ សុខាវ័ត្ន កួយ**

រដ្ឋរ៉ូដអាយលិន កាលពីថ្ងៃអង្គារ៍ ទី៣ ខែ សីហា ឆ្នាំ ២០១៧ បានអនុម័តគម្រោងកម្មវិធីសាកល្បងរយៈពេលបួនឆ្នាំដែលមានឈ្មោះថា “Promise Scholarship” ដោយផ្តល់អាហារូបករណ៍សិក្សាថ្នាក់មហាវិទ្យាយ័យដោយមិនគិតថ្លៃ។ គម្រោងអាហារូបករណ៍នេះ នឹងរ៉ាប់រងក្នុងការចំណាយសិក្សាថ្នាក់មហាវិទ្យាល័យដល់សិស្សថ្មីដែលនឹងចុះឈ្មោះនៅសាលារ៉ូដអាយលិន ខាំញូ នីធី ខលលិច (Community College of Rhode Island) ដោយមិនគិតពីកំរិតនៃប្រាក់ចូលរបស់សិស្សឡើយ មានន័យថា សិស្សថ្មីដែលចុះឈ្មោះបន្តការសិក្សាថ្នាក់មហាវិទ្យាល័យនៅសាលារ៉ូដអាយលិន ខាំញូនីធី ខលលិច នឹងមិនមានការចំណាយបង់ថ្លៃសិក្សានោះទេ។

លោកស្រីអភិបាលរដ្ឋ ជីណា អេម រេម៉ុនដូ បានមានប្រសាសន៍កាលពីថ្ងៃទី៣ ខែសីហា ថា កម្មវិធីនេះ គឺជា




ផ្នែកមួយនៃថវិការរបស់រដ្ឋ ដើម្បីជួយដល់ពលរដ្ឋនៅរ៉ូដអាយលិន ហើយរ៉ូដអាយ លិន គឺជារដ្ឋដំបូងគេបំផុតនៅតំបន់ឆ្នេរខាងកើត ដែលបង្កើតឱ្យមានការចូលរៀនមហាវិទ្យាល័យដោយមិនគិតថ្លៃនៅសាលារដ្ឋសម្រាប់សិស្សដែលបញ្ចប់ថ្នាក់វិទ្យាល័យ។

ដើម្បីទទួលបានអាហារូបករណ៍សិក្សាដោយមិនគិតថ្លៃនេះ បេក្ខជនត្រូវតែជាអ្នករស់នៅរ៉ូដអាយលិន, បានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ នៅឆ្នាំ២០១៧ រឺកាលនៅរដូវផ្ការីកថ្មីៗនេះ រឺក៏បេក្ខជនដែលមាន GED មានអាយុតិចជាង១៩ឆ្នាំ នៅពេលបញ្ចប់វិទ្យាល័យ។ ជាងនេះទៅទៀត បេក្ខជនតម្រូវឱ្យចុះឈ្មោះរៀនពេញម៉ោង និងត្រូវរក្សា GPA ឱ្យបាន 2.5។

ក្នុងកាដាក់ពាក្យសុំ Promise Scholarship នេះ បេក្ខជនអាចបំពេញពាក្យសុំតាមអនឡាញដោយចូលទៅកាន់វ៉ិបសាយរបស់សាលារ៉ូដអាយលិនខាំញូនីធី ខលលិច (https://www.ccri.edu /oes/admissions/apply.html) រួចចំពេញព័តិតាមការណែនាំ។ បន្ទាប់ពីដាក់ពាក្យសុំនៅសាលារ៉ូដអាយលិន ខាំញូនីធី ខលលិច រួចហើយ បេក្ខជនក៏តម្រូវឱ្យដាក់ពាក្យទៅកាន់កម្មវិធីស្នើសុំជំនួយថវិការក្នុងការសិក្សារបស់សហព័ន្ធដែលហៅកាត់ FAFSA ហើយត្រូវធ្វើការប្រឡងវាស់ស្ទង់សមត្ថភាពកម្រិតយល់ដឹង (Placement test) នៅសាលារ៉ូដអាយលិន ខាំញូនីធី ខលលិច ផងដែរ។

ចំពោះសិស្សដែលបានបង់ថ្លៃសិក្សារួច រឺបានបង់ខ្លះៗហើយនោះ នឹងបាទទួលចំនួនទឹកប្រាក់មកវិញ ប្រសិនបើពួកគេជាប់ឈ្មោះទទួលបានអាហារូបករណ៍នេះ។ សម្រាប់សាលារ៉ូដអាយ លិន ខាំញូនីធី ខលលិច នឹងចាប់ផ្តើមបើកវិសមកាលចូលរៀននៅរដូវឈើជ្រុះស្លឹកខែក្រោយនេះ។

ដូច្នេះនៅមិនទាន់យឺតពេលសម្រាប់សិស្សានុសិស្សជាពិសេសសម្រាប់ពលរដ្ឋខ្មែរដែលរស់នៅក្នុងរ៉ូដអាយលិនក្នុងការដាក់ពាក្យសុំអាហារូបករណ៍នេះ ដោយថ្ងៃផុតកំណត់នៅការដាក់ពាក្យសុំអាហារូបករណ៏នេះគឺថ្ងៃទី២៥ ខែសីហា។ គួរបញ្ជាក់ថាសម្រាប់សិស្សដែលបានទទួលអាហារូបករណ៏នេះ ត្រូវបានតម្រូវឱ្យរស់នៅ, ធ្វើការ រឺបន្តការសិក្សានៅក្នុងរ៉ូដអាយលិន បន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យនេះ។

ទាក់ទិនកម្មវិធីអាហារូបករណ៍នេះខ្មែរផុសមិនអាចទំនាក់ទំនងទៅកាន់លោកស្រី ចាន់ ណារី ឆាយ ដែលជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌល ដើម្បីអាស៊ាន (CSEA) ប្រចាំរ៉ូដអាយលិន ដើម្បីសុំធ្វើបទសម្ភាសន៏បានទេកាលពីថ្ងៃសុក្រសប្តាហ៏មុនដោយលោកស្រីមានការមមាញឹកជាមួយការងារក្នុងខែនេះ។

នៅសហរដ្ឋអាមេរិក រ៉ូដអាយលិន បាន ក្លាយជារដ្ឋទីប្រាំហើយដែលមិនមានការបង់ថ្លៃសិក្សាថ្នាក់មហាវិទ្យាល័យ បន្ទាប់ពីញូយក, អូរីហ្គិន, ថិននេសស៊ី និងសាន់ហ្វ្រាន់ស៊ីស្កូ។ នៅ ថិននេសស៊ី កម្មវីធីនៃការសិក្សាថ្នាក់មហាវិទ្យាល័យដោយមិនបង់ថ្លៃបានចាប់ផ្តើមនៅឆ្នាំ២០១៥ ដោយមានលក្ខខណ្ឌនៃការចុះឈ្មោះដូចគ្នាទៅនឹងរ៉ូដអាយលិន ហើយនៅអូរីហ្គិនបានដំណើរការនៅឆ្នាំ២០១៦ តែមិនមានរៀបបញ្ចូលចំពោះគ្រួសារដែលមានចំណូលខ្ពស់នោះទេ។ ចំណែកនៅញ៉ូយក និងនៅក្រុងសាន់ហ្វ្រាន់ស៊ីស្កូ គឺបានចាប់ផ្តើមនៅដើមឆ្នាំ២០១៧នេះ៕


បង់ថ្លៃបូកផ្សំ $0

ណាត់ជួបវេជ្ជបណ្ឌិត $0 ការមើលថែធ្មេញ $0 សេវាចក្ខុវិញ្ញាណ $0

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth រួមបញ្ចូលទាំងការធានាលើថ្នាំតាមវេជ្ជបញ្ជា Part D បូកផ្សំនឹងអត្ថប្រយោជន៍ច្រើនទៀតដូចជា៖

- ប័ណ្ណ OTC សម្រាប់ទិញថ្នាំ និងផលិតផលិតផលទាក់ទងនឹងសុខភាពជាក់លាក់ដែលមិនចាំបាច់វេជ្ជបញ្ជា *(រហូតដល់ $300 ក្នុងមួយឆ្នាំ ឬ $75 ក្នុងមួយត្រីមាស)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំគិលានុបដ្ឋាកដែលសម្របសម្រួលការមើលថែទាំរបស់អ្នកដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក។

ទាំងអស់ក្នុងផែនការងាយស្រួលតែមួយពី **Senior Whole Health**។

SWH SENIOR WHOLE HEALTH®

Simple. Secure. Independent.




ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare Part A និង/ឬ Part B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
(លេខឥតគិតថ្លៃ) **TTY/TDD:711**
**www.seniorwholehealth.com/SNP**
យើងបើកពីម៉ោង 8 ព្រឹកដល់ 8 យប់
7 ថ្ងៃក្នុងមួយសប្តាហ៍។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវបដណ្តប់ និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។*
*ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY/TDD: 711).*
*ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY/TDD: 711).*

សុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា (HMO SNP) និងសុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS។ ការចុះឈ្មោះធ្វើឡើងតាមការស្ម័គ្រចិត្ត និងអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។ ព័ត៌មាននេះពុំមែនជាការពិពណ៌នាពេញលេញនៃអត្ថប្រយោជន៍ឡើយ។ ទាក់ទងផែនការនេះសម្រាប់ព័ត៌មានបន្ថែម។ អាចនឹងមានការដាក់កម្រិត ការបង់ថ្លៃបូកផ្សំ និងការកំហិត។ អត្ថប្រយោជន៍អាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ សហចំណាយអាចប្រែប្រួលអាស្រ័យលើកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទំនាក់ទំនងទៅផែនការសម្រាប់ព័ត៌មានលម្អិតបន្ថែម។ ផែនការនេះអាចប្រើបានសម្រាប់អ្នកអាយុ 65 ឆ្នាំឡើងទៅ ដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare។ H2224_2016_138kh Accepted 11/25/2016

ព័ត៌មានខ្លីៗ

# លោកស្រីតំណាងរាស្ត្រ នីគី សុងគ្វាស មិនឈរជាបេក្ខជនទៀតទេ

**ខ្មែរផុសស.រ.អា**

លោកស្រី នីគី សុងគ្វាស ជា"តំណាងរាស្ត្រសហរដ្ឋ"បានប្រកាសកាលពីថ្ងៃទី៩កក្កដានេះថា លោកស្រីនឹងមិនឈរឈ្មោះក្នុងតំណែងឈ្មោះជាដំណាងរាស្ត្រលោកស្រីមានសេចក្តីរំភើបណាស់ ដោយរដ្ឋម៉ាសឈូសិតបានបញ្ជូនស្រីតំបូងបង្អស់ឱ្យទៅអង្គុយនៅព្រឹទ្ធសភា...ក្រោយមកក៏មានស្ត្រីផ្សេង ចូលមកកាន់កន្លែងធ្វើច្បាប់




លោកស្រីជាបន្តរទៅទៀតទេ នាឆ្នាំ២០១៨នេះ បន្ទាប់ពីលោកស្រីបានជាប់ឈ្មោះជាតំណាងរាស្ត្រចំនួន១០ឆ្នាំបន្តបន្ទាប់គ្នារួចមក ។

លោកស្រីបានប្រាប់ឡូសាន់ថា"កាលពី១០ឆ្នាំមុន នៅពេលដែលលោកស្រីស្ម័គ្រចិត្តឈរបានកើនចំនួនបានជាង៥០ភាគរយហើយ ។

ការប្រកាសដកខ្លួននេះ បានបើកផ្លូវឱ្យអ្នកនយោបាយផ្តើមការប្រកួតដណ្តើមអាសនៈតាំងពីឥឡូវនេះទៅហើយ ៕

ទីផ្សារផលិតផលកសិកម្មរបស់កសិករនៅឡូវែល

COMM UNITY TEAM WORK

ថ្ងៃសុក្រ ទី៧ ខែកក្កដា ថ្ងៃទី ១៣ ខែតុលា
ម៉ោង ១២ រសៀល ដល់ម៉ោង ៥ ល្ងាច
នៅសួន លូស៊ី ឡាខំ ជាក
ផ្លូវ ២៥៨ ម៉ែរីមាក ស្ទ្រីត

ARAMARK building community



បន្លែស្រស់ៗ, អាហារបំរុងរាងកាយ, ផលិតផលដែលធ្វើដោយដៃ និងមានអ្វីៗជាច្រើនប្រភេទផ្សេងទៀត

សប្បាយជាមួយក្រុមគ្រួសារ!

រីករាយជាមួយនឹងការរៀបចំកម្មវិធីទីផ្សារផលិតផលកសិកម្ម!
ការដាក់តាំងបង្ហាញផលិតផលម្ហូបអាហារ!
ដន្ត្រី, ល្បែងកំសាន្ត និងការចាប់រង្វាន់!
ទទួលយកអ្នកដែលមាន WIC, ប័ណ្ណចាស់ជរា,ប័ណ្ណSNAP/EBTនិងក្រេឌីតកាត

ចំណាយទិញផ្លែឈើ និងបន្លែស្រស់ៗពីកសិដ្ឋាននៅទីផ្សារផលិតផលកសិកម្មរបស់កសិករដោយប្រើប្រាស់ប័ណ្ណ SNAP របស់លោកអ្នក ហើយចំនួននៃការចំណាយទិញរបស់លោកអ្នក នឹងត្រូវបានបូកបញ្ចូលបន្ថែមទៅក្នុងប័ណ្ណ EBT របស់អ្នក!

www.commteam.org/farmers-market

ចុះឈ្មោះដោយ Sign up ដើម្បីទទួលព្រឹត្តិប័ត្រព័ត៌មានរបស់យើង
មានសំនួរ? សូមអ៊ីម៉េលទៅកាន់ ស៊ី ប្រ៊ីធិន: sbrittain@commteam.org
#lowellfarmersmarket #liveatthemarket

Effective Date September 6, 2017

The LRTA is pleased to announce the addition of Route 20



This new route will provide a direct connection between Downtown Lowell and UMass Lowell North Campus.

Bus Service Hours: Monday through Friday 7 am to 11 am

Lowell Regional Transit Authority




FOR MORE INFORMATION: WWW.LRTA.COM

## តមកទំព័រទី ០៣ ព្រឹត្តិការណ៍ប្លែកៗនៅសេតវិមាន...

បណ្តាញគ្រប់គ្រងព័ត៌មាននៅសេដ្ឋវិមានទៅតាមគំនិតរបស់ប្រធានាធិបតី,បូកគ្នានឹងទស្សនៈយកកូនប្រុសកូនស្រីនឹងកូនប្រសារមកធ្វើជាមន្ត្រីជាន់ខ្ពស់របស់ប្រធានាធិបតីអាមេរិកកាំងបានធ្វើឱ្យមានការទិទៀនកាន់តែច្រើនឡើងក្នុងបណ្តាអ្នកធ្លាប់គាំទ្ររបស់ ឌុណាល ត្រាម ដែលបានធ្វើឱ្យការស្ទង់មតិពីប្រជាប្រិយភាពរបស់ប្រធានាធិបតី ត្រាម កាន់តែចុះថែមទៀត មកនៅត្រឹមតែ៣៩% ក្នុងចំណោមអ្នកដែលធ្លាប់តែគាំទ្រ ឌុណាល ត្រាម ពីមុនមក ។នៅសេដ្ឋវិមាន រូបថតមួយដែលបង្ហោះពីបុគ្គលិកបំរើការថ្មីរបស់ ប្រធានាធិបតីថ្មីអាមេរិកាំងមិនមានបុគ្គលិកស្បែកផ្សេងពី ពួកស្បែកសទេ, ទស្សនៈទាំងអស់នេះហើយ ដែលមិនដូចគ្នាពីចរន្តទស្សនៈរបស់ប្រធានាធិបតីមុនៗ មិនថា"គណបក្សសាធារណរដ្ឋ"ឬក៏"គណបក្សប្រជាធិបតេយ្យ"ទេ នេះក៏ជារូបភាពនៃទស្សនៈប្លែកៗថ្មី នៅសេដ្ឋវិមានដែរ ។

អស់ជាង៦ខែមកហើយដែល ឌុណាល ត្រាម កាន់ដំណែងជាប្រធានាធិបតី ក៏ប៉ុន្តែរវល់ចង់កែនឹងដាក់ច្បាប់"សុខភាពពលរដ្ឋ"ថ្មី ដោយគណបក្សសាធារណរដ្ឋតែធ្វើមិនបានសោះបរាជ័យច្រើនដងទម្រាំរហូតដល់សប្តាហ៍មុននេះក៏"រលូត"ចេញមកបានដោយសារការបង្ខំពីប្រធានាធិបតីផងហើយក៏មានការកែប្រែបន្តិចបន្តួចលើច្បាប់"អូបាមា"ចាស់, ពីព្រោះក្រុមខាងគណបក្សសាធារណរដ្ឋខ្លួនឯង ពុំបាននឹកគិតថា "នឹងបានទទួលដំណែងខ្ពង់ខ្ពស់បំផុត ជាប្រធានាធិបតីផងទេ" ម្ល៉ោះហើយក៏ពុំបានត្រៀមគម្រោងកែប្រែច្បាប់នេះឱ្យបានយូរពីមុនមកទេ។

ចំពោះទំនាក់ទំនងកិច្ចការបរទេសវិញ គេអាចសង្កេតឃើញថា ប្រទេសធំៗជាច្រើនបានរសាយចិត្តឃ្លាតចេញពីទំនាក់ទំនងល្អរបស់អាមេរិក



មានៈ

*នៅសហភាពអឺរ៉ុប អាក់អន់ស្រពន់ចិត្តដោយសារអាមេរិកប្រកាសដកខ្លួនចេញពីប្រព័ន្ធការពារបរិយាកាសកំដៅពិភពលោក, *នៅអង្គការ"ណេតូ"សហរដ្ឋអាមេរិកបានធ្វើឱ្យប្រទេសតូចៗជាសម្ព័ន្ធមិត្តរួមចម្បាំងអាក់អន់ចិត្តដោយសារការទារលុយចូលរួមចម្បាំងដែលពួកគេមិនបានផ្តើម ឬមិនចង់ធ្វើ, *ចំណែកឯប្រទេសរុស្សីវិញ គេបានបណ្តេញបុគ្គលិកទូតអាមេរិកាំង៧៥៥នាក់ពីប្រទេសគេដោយការដាក់ទណ្ឌកម្មចំពោះប្រទេសគេពីរឿងរុស្សីលូកដៃកក្កូរក្នុងរឿងបោះឆ្នោតនៅសហរដ្ឋអាមេរិកដែលក្នុងនោះក៏នៅមានក្រុមគ្រួសារខ្លួនឯងពាក់ពន្ធក្នុងនោះដែរ, *នៅមានប្រទេសចិនដែលអាមេរិកកាត់បន្ថយទំនាក់ទំនងសេដ្ឋកិច្ចទៅវិញទៅមកបណ្តាលឱ្យចិនរកផ្លូវយុទ្ធសាស្ត្រសេដ្ឋកិច្ចថ្មីនៅអឺរ៉ុបនឹងនៅមជ្ឈឹមបូពា, *នៅមានអាស៊ានដែលកំពុងត្រូវចិនអូសទាញចេញពីសម្ព័ន្ធមិត្តអាមេរិកាំង យកទៅខាងគេដូចជាមានហ្វីលីពីន នឹងកម្ពុជា... ហើយអាមេរិកាំងមិនបានបញ្ចេញឥទ្ធិពល ឬសកម្មភាពអ្វីដូចប្រធានាធិបតីខាង"សាធារណរដ្ឋ"មុនៗនោះទេ ។ ...។ល ។

នៅកូរ៉េខាងជើង ប្រធានាធិបតី គីម យ៉ុងអូន បានបាញ់កាំជ្រួចបរមាណូសាកជាច្រើនដងបណ្តាលឱ្យមានការភ័យស្លន់ស្លោដល់ប្រទេសជិតខាងដែលនឹកថានឹងអាចមានកើតសង្គ្រាមនោះតែអាមេរិកបានត្រឹមតែដាក់នាវាចម្បាំងព័ទ្ធកូរ៉េខាងជើង ហើយអ.ស.ប. ក៏បានត្រឹមតែដាក់សម្ពាតហើយរង់ចាំប្រទេសចិនជាអ្នកធ្វើសកម្មភាពទណ្ឌកម្មលើកូរ៉េខាងជើង ប៉ុន្តែគឺជាការប្រឹងប្រែងមិនទាន់បានផល ពីព្រោះចិនហាក់ដូចជាចង់អូសបន្លាយមិនទាន់ចង់ឱ្យមានការវិវត្តន៍អ្វីឡើយ ពីព្រោះវត្តមានរបស់ទ័ពអាមេរិកាំងនៅសមុទ្រចិនមិនគួរជាទិកក់ក្តៅទេ។ ចុងក្រោយបង្អស់ មានការដាក់ទណ្ឌកម្មលើកូរ៉េខាងជើងដោយ អ.ស.ប. ១៥សម្លេងទល់នឹង0 គឺចូលរួមទាំងចិននឹងរុស្សីផង ធ្វើឱ្យការដាក់ទណ្ឌកម្មនេះមានភាពធ្ងន់ធ្ងរបំផុត គេសង្ឃឹមថាមិនត្រឹមតែជាទណ្ឌកម្មសេដ្ឋកិច្ចអាចនឹងមានការវាយប្រហារលើកូរ៉េខាងត្បូងយ៉ាងហោចណាស់ ក៏វាយកំទេចទីតាំងមីស៊ីលបរមាណូដែរ។ បន្ទាប់ពីចិនបានគម្រាមកូរ៉េខាងជើងកាលពីថ្ងៃអាទិត្យនេះមក គីម យ៉ុងអ៊ុន



ស្ទីវ បាណុន ទីប្រឹក្សាប្រធានាធិបតី ក៏ត្រូវចេញ

ហាក់ដូចជាបានបន្ទន់ឥរិយាបទបន្តិចនៅថ្ងៃចន្ទបន្ទាប់, នៅពេលដែល ស.រ.អា. ត្រៀមប្រយុទ្ធនឹងច្រកគ្រាប់រួចជាស្រេចមក។

ចំណែកសង្គ្រាមនៅឯមជ្ឈឹមបូពារប្រទេសស៊ីរីបានស្ងប់ស្ងាត់ដោយសង្គ្រាមក្នុងស្រុកបន្តិចមែនដោយក្រុមភេរវករបានបាត់បង់មូលដ្ឋាន"មូស៊ូល"ដែលយកបានដោយទ័ពអាមេរិកាំង ក៏ប៉ុន្តែរដ្ឋាភិបាលប្រទេស"ស៊ីរី"បែរជាទៅចូលជាមួយរុស្សីពង្រឹងអំណាចជាមួយយោធាក្នុងស្រុករបស់ខ្លួនដែលគ្មានពលរដ្ឋគាំទ្រទៅវិញ, សហរដ្ឋអាមេរិកធ្លាប់តែនៅជិតចលនាតស៊ូរបស់ពលរដ្ឋស៊ីរីយ៉ាមិនឃើញមានសញ្ញាណាមួយថា នៅជាមួយថាលូកដៃទៅគាំទ្រចលនានោះឱ្យពេញទំហ៊ឹងនៅឡើយទេ ។ ការដាក់ទណ្ឌកម្មរបស់អាមេរិក ដល់កូរ៉េខាងជើង អ៊ីរ៉ង់ នឹងរុស្សី អាចនឹងត្រូវគេមើលឃើញថា ជម្រុញ "ស៊ីរី"ឱ្យទៅក្នុងដៃចលនា"មូសស្លីម"ទៅវិញ៕


សមាគមបាល់ទាត់ យុវជននៅឡូវែល

Lowell Youth Soccer Association

Fall Registration — ចុះឈ្មោះសម្រាប់រដូវរងា

Teams are available for — នៅសល់កន្លែងទំនេរ

Ages 3-11 Recreation League — អាយុ ៣-១១ឆ្នាំ ក្រុមហាត់ទាត់បាល់

9-14 Travel League - — អាយុ ៩-១៤ ឆ្នាំ ចាប់ផ្តើមប្រកួត

* Limited positions are available - Boys and Girls Under-10 - - Under-14

កំណត់កន្លែងដែលនៅសល់ -ក្មេងស្រី និងក្មេងប្រុសអាយុតិចជាង១០ឆ្នាំ -អាយុតិចជាង១៤ឆ្នាំ



Register On-line at: lowellsoccer.com




### ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

**ព្រឹត្តិការណ៍ខុសប្រក្រតីរបស់ប្រទេសកម្ពុជា**

ករណីអ្នកស្រី **ទេព វន្នី** ត្រូវគេចាប់ដាក់គុកជាច្រើនលើក ដោយអ្នកស្រីមានស្មារតីដ៏មុតមាំការពារយុត្តិធម៌ជូនអ្នកដែលត្រូវគេរំលោភ ដូចជាប្រមូលផ្តុំគ្នាសុំឲ្យគេដោះលែងមន្ត្រីអង្គការការពារសិទ្ធិមនុស្ស **អាដហុក** ៥នាក់ ដែលត្រូវគេចាប់ឃុំដោយអយុត្តិធម៌ជាដើម។ ការកាត់ទោសថា អ្នកស្រីបានវាយភ្នាក់ងារសន្តិសុខ នេះគ្រាន់តែជាលេសដើម្បីចាប់ខ្ទប់មាត់ ពេលណាដោះលែងនៅលើផែនការរបស់ថ្នាក់លើ។

សកម្មជនរបស់គណបក្សសង្គ្រោះជាតិជាង១០នាក់ បានត្រូវគេកាត់ទោសឲ្យជាប់គុកពី៧ឆ្នាំទៅ២០ឆ្នាំ ពីបទចោទថាបានវាយភ្នាក់ងារសន្តិសុខ។ តើការវាយនោះ មានរបួសប៉ុន្មាននាក់ ស្លាប់ប៉ុន្មាននាក់ បានជាកាត់ទោសឲ្យជាប់គុករហូតដល់២០ឆ្នាំ ពេលជំនុំជំរះ តាមពត៌មានថា គ្មានឃើញអ្នកទាំងនោះដែលថាជាអ្នកដើមបណ្តឹង បានមកក្នុងពេលនោះឡើយ តើអ្នកចោទនេះជាការពិតទេ? អ្នកសង្កេតការណ៍មើលឃើញថា នេះជាផ្លូវនយោបាយសុទ្ធសាធ អ្នកណាខ្លាំងចាប់ដាក់គុក ។

លោក **សមរង្ស៊ី** ត្រូវច្បាប់គណបក្សនយោបាយចេញជាបន្តបន្ទាប់ពីរដង កំចាត់ចេញពីសែរៀន មុនការប្រកួតប្រជែងតំណែងនាយករដ្ឋមន្ត្រី ត្រូវតែរកបេក្ខជនឲ្យអន់ជាងនេះ ឬគ្មានគូប្រកួតតែម្តង ដោយបានជ័យជំនះមិនបាច់ប្រកួត។

ករណីលោក **ញ៉ិក ប៊ុនឆៃ** បន្ទាប់ពីបំបែកចេញពីទ្រង់រណប្ញទ្ធិហើយ បានត្រូវគេប្រើអស់សាច់ ដោយមើលឃើញថាមិនអាចយកជាកូនអុកបានទៀតទេ ត្រូវតែលះបង់ចោល ទោះបីចោទថា លោកញ៉ិក ប៊ុនឆៃ បានទូរស័ព្ទទៅមន្ត្រីគណបក្សសង្គ្រោះជាតិក៏ដោយ។ មិនត្រឹមតែទាត់ចោលទេ ខំគាស់កកាយរឿងកន្លងទៅជាង១០ឆ្នាំហើយយកមកសាកសួរ ឲ្យមានទោសឬយ៉ាងណាស្រេចតែថ្នាក់លើ។ពីមុនមានអ្នករត់ពីបក្សសង្គ្រោះជាតិទៅចូលបក្សប្រជាជន គេឲ្យបុណ្យស័ក្តិមួយពេល យូរទៅបាត់ឈ្មោះ៕

វត្តខ្មែរកាណាដា,ថ្ងៃ៤សីហា២០១៧;www.hoksavann.org;savannhok@yahoo.com

តមកទំព័រទី ០៤

# ពិពណ៌ចំរុះវប្បធម៌ឆ្នាំ២០១៧នៅឡូវែល




ហាក់ដូចជាគ្មានម្ហូបអាហារដែលត្រូវបង្ហាញគ្មានគ្រឿងអលង្ការតែងលំអរូបរាងកាយស្ត្រីគ្មានជំនាញអ្វីមួយដែលអាចនឹងចែករំលែកដល់អ្នកភូមិផងរបងជាមួយសោះ។ បើកុំតែបានសមាគមខ្មែរសមាគមខ្មែរលើកគ្នាទៅដង្ហែក្បួនថ្ងៃបើកឆាកទីមួយនៅមានសិល្បៈករចម្លាក់ នឹងស្ទួន យ៉ារី ឡឺវ៉ាន់ ម្នាក់ដែរ ដែលគេដាក់នៅក្បែរវិទ្យាល័យ កុំអីគេថា "មិនមានខ្មែរនៅទីនេះទេ"។ យើងបានប្រទះក្រុមយុវជន-យុវនារីខ្មែរមាំមួនស្រស់ស្អាតជាច្រើនរូបបាននាំគ្នាមកស្ម័គ្រ



ចិត្តជួយសកម្មភាព"ពិពណ៌ចម្រុះវប្បធម៌"នឹងសកម្មភាពសមាគម ឬពាណិជ្ជកម្មផ្សេងៗដែលសកម្មភាពទាំងនោះបានធ្វើឱ្យគេមើលមកសហគមន៍ខ្មែរថា មានកូនចៅសកម្មគ្រាន់បើដែរ។

"ពិពណ៌ចម្រុះវប្បធម៌ឆ្នាំ២០១៧នៅឡូវែល" នេះ បានទទួលអំណោយផលសំខាន់បំផុតពីធាតុអាកាសមេឃស្រឡះ កំដៅឡើង៧០-៨០អង្សា ធ្វើឱ្យការរៀបចំបង្ហាញទស្សនីយភាពទាំងអស់អាចប្រព្រឹត្តទៅតាមគម្រោងបានឥតខ្ចោះ ។ រថភ្លើង"ត្រលឡេ"ដែលគេរក្សាតាំងពី១០០ឆ្នាំមុននៅរត់បង្ហាញភាពសង្ហារបស់ខ្លួនដូចកាលពី១០០ឆ្នាំមុន នៅតាមចន្លោះផ្ទះថ្មខ្ពស់ធ្វើពីឥដ្ឋក្រហមដែលជាអតីតរោងចក្រតម្បាញនឹងតាមបណ្ដោយអូរសិប្បនិម្មិតដែលសាងសង់ឡើងសម្រាប់ដឹកទំនិញផង នឹងសម្រាប់បង្កើតអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងរោងចក្រតំបាញទាំងនោះធ្វើឱ្យក្រុងឡូវែលថ្ងៃនេះ ត្រឡប់ទៅបង្ហាញអតីតកាលដ៏រុងរឿងដោយសកម្មភាពឧស្សាហកម្មតំបាញដ៏ធំសម្បើមមួយដែលធ្លាប់បានតាំងទីនៅកន្លែងនេះ។

នាថ្ងៃសៅរ៍នឹងអាទិត្យ ទូរទស្សន៍ "អិលទីស៊ី"បានធ្វើការផ្សាយបន្តផ្ទាល់ពីពិធីតាំងពិពណ៌នេះចំនួន៤ម៉ោង ក្នុងមួយថ្ងៃ, សូបិន នាយកខ្មែរផុស ក៏បានចូលរួមជាពិធីករក្នុងកម្មវិធីនោះនាថ្ងៃសៅរ៍, ជាខ្មែរផង ជាពិធីករផង សូបិនបានធ្វើឱ្យសារធារណជនបរទេសជាពិសេសយល់ពីសហគមន៍ខ្មែរបានកាន់តែច្រើនជាលំដាប់ ហើយតួនាទជាប្រព័ន្ធផ្សព្វផ្សាយ ក៏មានការកត់ត្រាចងក្រងទុកជាការចងចាំបានយូរអង្វែងទៅអនាគត។ មិនដូចកាលពីឆ្នាំមុន ភ្ញៀវមិនបានមកកកកុញដូចឆ្នាំនេះទេ អ្នកជួលតូបតាំងផលិតផល ពេទ្យសិល្បៈ សិក្សា អេឡិចត្រូនិក ម្ហូបអាហារ ឬទំនិញទំនងជាបានផលចំណេញគ្រប់ៗគ្នា...។ល។ ក្រុមភ្លេងបាននៅកំដរភ្ញៀវរហូតដល់ម៉ោង៨យប់នៃថ្ងៃអាទិត្យទទើបបានចប់សព្វគ្រប់ជាស្ថាពរ៕



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
### Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណ:ដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវ:
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកទំព័រទី ០១

## ពិធីបុណ្យអុំទូកនៅឡូវែល...

សម្រាប់បំពេញព្រែកជីកក្នុងក្រុងឡូវែល ហើយបង្វិលម៉ាស៊ីនភ្លើងសម្រាប់ប្រើប្រាស់ក្នុងឧស្សាហ៍កម្មសង្គ្រាមនៅសហរដ្ឋអាមេរិក។

**កីឡាករ៧ក្រុម មាន៖** 1-Dragon Boat Z 2- Lady Klahan 3-Payanak 4- RI Phoenix 5-New England Top Gun 6-Angkorian Warriors 7-Brotherhood 0f Strenght ដែល

សុទ្ធតែល្បីច្រើនឆ្នាំមកហើយ បានប្រកួតគ្នាជាថ្មីម្តងទៀត ជាមួយនឹងទូកងរបស់សហគមន៍ឡាវ២ នៅលើទឹកទន្លេ"មេរីម៉ាក"។

នៅពេលដែលទូកកំពុងប្រណាំងយ៉ាងហ៊ឹកហ៊ាក់ក្នុងទន្លេ នៅលើច្រាំងឯណេះ តូបតូចៗប្រមាណ១០០ ក៏បានបញ្ចេញរបស់លក់ដូរនឹងបង្ហាញផលិតផលនៃប្រជាជនអាស៊ីអគ្នេយ៍យ៉ាងព្រោងព្រាត ទាក់ទាញអារម្មណ៍ភ្ញៀវគ្រប់ជាតិសាសន៍ឱ្យភ្លក្សរស់ជាតិម្ហូបអាហារពិសេសរបស់ប្រទេសខ្មែរ លាវ នឹងថៃ រួមទាំង ចិន វៀតណាម ដែលជាជនជាតិថ្មីមករស់នៅដែនដីថ្មី ។ មនុស្សម្នា












បុគ្គលិកសាលាក្រុង


បេក្ខជនសាលាក្រុង ផល រដ្ឋាយ៉ែម




បេក្ខជនគណកម្មការសាលារៀន

ប្រជ្រៀតគ្នាទិញទឹកអំពៅកិន ទិញទឹកកក ឈូសនៅមានសាច់គោអាំង ឬមាន់អាំងដ៏ឈ្ងុយឆ្ងាញ់សម្រាប់ហូបជាមួយបាយដំណើបផ្អាប់ជាមួយញាំល្ហុង ដ៏ហិលរបស់ជនជាតិឡាវ ។ មានពាណិជ្ជករលក់កូនឈើ មាក្រូចសើច មានដើម ស្លឹកគ្រៃដើមផ្កានាស្រុកអាស៊ីយើងតូបខ្លះទៀតដាក់ផ្ទាំងគំនូរអង្គរវត្តខ្មែរ ឬក៏ជីវភាពប្រជាជនជនបទនៃស្រែចំការខ្មែរ...។

ប្រទេស៣ មានខ្មែរ ឡាវនឹង ថៃ បានដណ្តើមបង្ហាញពីប្រវត្តិជាម្ចាស់នៃបុណ្យអុំទូកតែរៀង១ខ្លួន តែពុំមាននរណាមានទំនាស់ពីប្រវត្តិដើមនៃពិធីដ៏មានប្រជាប្រិយនេះទេ គឺជាការរួមរស់ប្រកបដោយភាពចុះសម្រុងគ្នាឥតប្រកែរប្រកាន់កសាងជីវិតថ្មីយ៉ាងសុខសាន្ត៕






# ពាក្យបណ្តឹងអំពីសិទ្ធិបោះឆ្នោតនៅក្រុងឡូវែល–សម្អាងហេតុ

## សាលាដំបូងសហរដ្ឋអាមេរិក / សាលាដំបូងរដ្ឋមាសាឈូសេត
## ដើមបណ្តឹង ទល់នឹង ចុងបណ្តឹង

សំណុំរឿងលេខ:..........................

ពាក្យបណ្តឹង សុំដីការរក្សាការពារ និងរបតិវេសនីណោះស្រាយស្នើសុំជម្រះក្តីដោយក្រុមជំនុំជម្រះ

### សេចក្តីផ្តើម

**១–**សិទ្ធិបោះឆ្នោត និងគោលការណ៍នៃសម្លេងឆ្នោតមួយសន្លឹករបស់ជនគ្រប់រូបមានតម្លៃស្មើគ្នា ជាមូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យរបស់យើង ។ ដើមបណ្តឹងមួយភាគធំ គឺជាប្រជាពលរដ្ឋសហគមន៍ក្រុងឡូវែល និងពលរដ្ឋសហគមន៍ជនជាតិភាគតិចដែលនាំគ្នាដាក់ពាក្យបណ្តឹង សុំខ្ញុំពង្រឹងការអនុវត្តច្បាប់ជាតិដែលការពារសិទ្ធិជាមូលដ្ឋាននេះ ។ ដើមបណ្តឹងប្តឹងជំទាស់ ជាពិសេសទៅនឹងប្រព័ន្ធបោះឆ្នោតបែបមិនសមមាត្រនៅទីក្រុងឡូវែលដែលប្រព័ន្ធបែបនេះ គឺខុសច្បាប់ និងផ្ទុយពីរដ្ឋធម្មនុញ្ញ ហើយធ្វើសហគមន៍ជនជាតិភាគតិចនៅទីក្រុងឡូវែលបាត់សម្លេងរបស់ខ្លួន។ ពួកគាត់បាត់បង់សិទ្ធិស្មើគ្នាក្នុងការបោះឆ្នោតជ្រើសរើសតំណាងដែលខ្លួនពេញចិត្តក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុងឡូវែល និងបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការសាលាក្រុងនៅទីក្រុងឡូវែល ។

**២–**ស្ថិតិនៃចំនួនប្រជាជនបញ្ជាក់យ៉ាងច្បាស់ ថាទីក្រុងឡូវែលសព្វថ្ងៃមានប្រជាពលរដ្ឋភាគច្រើនជាជនជាតិភាគតិច ពោលគឺជនជាតិភាគតិចមានចំនួនលើសពី៤៩% នៃចំនួនប្រជាជនសរុបនៃទីក្រុងឡូវែល ។ នៅទីក្រុងឡូវែលមានពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិកឡាទីន ឬអេស្ប៉ាញមានចំនួន40%នៃចំនួនពលរដ្ឋសរុប ។ ប៉ុន្តែក្រុមប្រឹក្សាក្រុងឡូវែលដែលមានសមាជិក៩រូប គឺគឺសុទ្ធតែជនជាតិស្បែកសទាំងអស់ ។ តាំងពីដើមមកជនជាតិស្បែកស នៅតែគ្រប់គ្រងសមាជិកក្រុមប្រឹក្សាក្រុងឡូវែលរហូត។ ចំណែកឯគណៈកម្មាធិការសាលាដែលមានសមាជិក៦រូបវិញ គឺសុទ្ធតែជាជនជាតិស្បែកសទាំងអស់ដូចគ្នា ។ គ្មានជនជាតិភាគតិចណាម្នាក់ធ្លាប់បានធ្វើជាតំណាងនៅក្នុងសមាជិកគណៈកម្មាធិការសាលានេះម្តងណាឡើយ ។

**៣–**ភាពខ្វះសមាជិកតំណាងមកពីគ្រប់ជាតិសាសន៍នៅក្នុងសមាសភាពនៃសមាជិកក្រុមប្រឹក្សាក្រុងឡូវែល និងក្នុងគណៈកម្មាធិការសាលាបែបនេះ គឺបណ្តាលមកពីប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រដែលអ្នកឈ្នះយកទាំងអស់នេះឯង ។ ក្នុងប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនៅទីក្រុងឡូវែលសព្វថ្ងៃដែលអ្នកឈ្នះទាំងអស់នេះ បេក្ខជនដែលបានសម្លេងឆ្នោតគាំទ្រត្រឹមតែ៥១%ប៉ុណ្ណោះ គឺអាចគ្រប់គ្រងកៅអីទាំងអស់ និងឈ្នះគ្រប់ការបោះឆ្នោត ។ នេះហើយគឺជាអ្វីដែលកំពុងកើតមាននៅទីក្រុងឡូវែល។ ទំនោរនៃការបោះឆ្នោតបង្ហាញឱ្យឃើញនៅការបំបែកពូជសាសន៍ដ៏ទៃដោយជនជាតិស្បែកសដែលចេញមកបោះឆ្នោតច្រើន ជាទូទៅបោះឆ្នោត ដើម្បីទប់កុំឱ្យសម្លេងខាងជនជាតិភាគតិចឈ្នះដែលប្រការនេះ ធ្វើឱ្យបាត់សម្លេងរបស់ម្ចាស់ឆ្នោតដែលជាជនជាតិអាមេរិកាំងដើមកំណើតអាស៊ី និងជនជាតិអាមេរិកាំងដើមកំណើត អាហ្វ្រិកឡាទីន និងអេស្ប៉ាញ ។ ការបាត់សម្លេងបែបនេះ បណ្តាលឱ្យប៉ះពាល់ដល់គោលការណ៍គ្រឹះនៃសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត និងរំលោភច្បាប់ជាតិ ។

**៤–**ភាពខ្វះតំណាងជនជាតិភាគតិចនៅក្នុងអង្គបោះឆ្នោតរបស់ទីក្រុងឡូវែលបែបនេះ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សហគមន៍ជនជាតិភាគតិចដែលសម្លេងឆ្នោតរបស់ពួកគាត់ត្រូវអស់តម្លៃ ។ សហគមន៍ជនជាតិភាគតិចនៅទីក្រុងឡូវែលខំប្រឹងតស៊ូ ដើម្បីទាមទារឱ្យក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលានៅទីក្រុងឡូវែលចាត់វិធានការណ៍ដោះស្រាយបញ្ហាសំខាន់ទាំងនេះ ។ រដ្ឋការគ្រប់កម្រិតខ្វះការយកចិត្តទុកដាក់លើសហគមន៍ជនជាតិភាគតិច ។ សាលាក្រុងមិនបាន ផ្តល់សេវា និងផលប្រយោជន៍ផ្សេងៗឱ្យបានស្មើគ្នាទៅដល់សហគមន៍ជនជាតិភាគតិចនោះទេ ។សហគមន៍ជនជាតិភាគតិចមិនសូវមានឱកាសចូលបំរើការងារនៅសាលាក្រុង ដូចជាខាងនាយកដ្ឋានប៉ូលិសក្រុងឡូវែល និងនាយកដ្ឋានសិក្សាធិការក្រុងឡូវែលជាដើម។

កូនសិស្សដែលជាកូនចៅរបស់ពលរដ្ឋសហគមន៍ជនជាតិភាគតិចជួបបញ្ហាប្រឈមជាច្រើនក្នុងសម្រេចគោលដៅសិក្សានៅសាលា និងទទួលទណ្ឌកម្មវិន័យស្មើភាពគ្នា ។ ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះ ធ្វើឱ្យអ្នកតំណាងដែលជាប់ឆ្នោតនៃសាលាក្រុងឡូវែលខ្វះឆន្ទៈក្នុងការជួយដោះស្រាយកង្វល់ និងសេចក្តីត្រូវការចាំបាច់របស់ពលរដ្ឋសហគមន៍ជនជាតិភាគតិច ។

**៥–**មន្ត្រីជាប់ឆ្នោតនៃសាលាក្រុងឡូវែល និងអ្នកបោះឆ្នោតដែលភាគច្រើនជាជនជាតិជាតិស្បែកសនាំគ្នារារាំងមិនឱ្យផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតចាស់គំរិលនេះ ។ **តទៅទំព័រទី១២**

# IN THE UNITED STATES DISTRICT COURT FOR THE DISTRICT OF MASSACHUSETTS

CHANMONY HUOT, VLADIMIR SALDAÑA, CHAMPA PANG, LIANNA KUSHI, THOEUN KONG, DENISSE COLLAZO, SUE J. KIM, SOADY OUCH, TOOCH VAN, CARMEN BERMUDEZ, KEI KAWASHIMA-GINSBERG, DANIEL K. UK, and FAHMINA ZAMAN, Plaintiffs,

v.

CITY OF LOWELL, MASSACHUSETTS; KEVIN J. MURPHY, in his official capacity as Lowell City Manager; LOWELL CITY COUNCIL; RITA M. MERCIER, RODNEY M. ELLIOTT, EDWARD J. KENNEDY, JR., JOHN J. LEAHY, WILLIAM SAMARAS, JAMES L. MILINAZZO, DANIEL P. ROURKE, COREY A. BELANGER, JAMES D. LEARY, in their official capacities as members of the Lowell City Council; LOWELL SCHOOL COMMITTEE; STEPHEN J. GENDRON, JACQUELINE DOHERTY, CONNIE A. MARTIN, ROBERT J. HOEY, JR., ROBERT JAMES GIGNAC, ANDRE DESCOTEAUX, in their official capacities as members of the Lowell School Committee; LOWELL ELECTION AND CENSUS COMMISSION; and BEVERLY ANTHES, JOSEPH MULLEN, THEL SAR, THOMAS FR. O'BRIEN, in their official capacities as members of the Lowell Election and Census Commission, Defendants.

Case No. ________________

COMPLAINT FOR INJUNCTIVE AND DECLARATORY RELIEF

JURY TRIAL DEMANDED

**INTRODUCTION**

1. The right to vote—and the principle that everyone's vote should count equally—is at the very core of our democracy. Plaintiffs are members of the City of Lowell's large and growing minority community who bring this lawsuit to enforce the federal laws that protect this fundamental right. Specifically, Plaintiffs challenge Lowell's at-large plurality municipal electoral system, which unlawfully and unconstitutionally dilutes the vote of minorities in Lowell and deprives them of an equal opportunity to elect candidates of their choice to the Lowell City Council and Lowell School Committee.

2. The numbers are stark. Lowell today is on the cusp of being a majority-minority city, with minorities constituting more than 49% of Lowell's total population. Lowell's Asian- American and Hispanic/Latino communities by themselves constitute nearly 40% of the city's total population. Yet the nine-member Lowell City Council is currently all-white, and has been so for virtually all of Lowell's history. The six-member Lowell School Committee is similarly all-white, and, to Plaintiffs' knowledge, has never had a single minority representative.

3. The lack of diversity of the Lowell City Council and Lowell School Committee is a direct result of Lowell's at-large plurality municipal electoral system. In an at-large plurality winner-take-all system such as Lowell's, 51% of the electorate can control all the seats and win every election. That is precisely what is occurring in Lowell. Voting patterns show demonstrable racial polarization, with a predominantly white majority that generally votes as a bloc, effectively diluting and canceling out the votes of Asian-Americans and Hispanics/Latinos.

This is directly counter to the fundamental principle of equal voting opportunity, and in violation of federal law.

4. The lack of diversity on Lowell's elected bodies has had, and continues to have, a detrimental impact on the minority communities whose votes are diluted. Lowell's minority communities struggle to get the Lowell City Council and the Lowell School Committee to take actions on matters that are important to those communities. Outreach to communities of color, including translation services, is lacking at all levels of government. City services and amenities are unequally distributed. Minorities are significantly under-represented in city jobs—including in the Lowell Police Department and in the Lowell Public Schools—and minority students face achievement gaps and disparities in school discipline. Lowell's elected officials are unaccountable to Lowell's minority communities under the city's at-large plurality election system, however, providing little motivation for them to be responsive to minority communities' needs or concerns.

5. Lowell's elected officials—and predominantly white majority voters in the city— have resisted recent efforts to change Lowell's outdated election system. Lowell remains the last holdout among large Massachusetts cities in clinging to an exclusively at-large plurality municipal electoral system—a system that was implemented in Lowell in the 1950s with the declared intent of limiting minority participation in the political process. Judicial intervention is therefore necessary to protect the rights of the large and growing number of minority residents of Lowell whose votes are unlawfully diluted by Lowell's at-large electoral system.

**Continued to Page 12**

តមកទំព័រទី ១១

## ពាក្យបណ្តឹងអំពីសិទ្ធិបោះឆ្នោត...

ទីក្រុងឡូវែលជាក្រុងចុងក្រោយគេ ក្នុងចំណោមក្រុងធំៗទាំងឡាយក្នុងរដ្ឋម៉ាសាឈូសេត ដែលនៅបន្តក្រាញចង់ទុកប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះតទៅទៀត ។ ប្រព័ន្ធចាស់គំរិលនេះ ត្រូវបានអនុវត្តនៅទីក្រុងឡូវែលតាំងពីដើមឆ្នាំ១៩៥០មកម្ល៉េះ ។ ការរារាំងមិនចង់ផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតបែបនេះ គឺជាចេតនាចង់បំបិទសម្លេងរបស់ជនជាតិភាគតិចក្នុងដំណើតការបោះឆ្នោត ។ ដូច្នេះ អន្តរាគមន៍ពីតុលាការ គឺពិតជាមានភាពចាំបាច់ខ្លាំង ដើម្បីការពារសិទ្ធិរបស់ជនជាតិភាគតិចដែលកាន់តែមានសម្លេងច្រើនឡើងនៅក្នុងទីក្រុងឡូវែលដែលសម្លេងឆ្នោតរបស់ពួកគាត់ត្រូវបានគេបំបិទចោលដោយសារប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនៅទីក្រុងឡូវែលនាពេលបច្ចុប្បន្ន ។

**៦-**ដើមបណ្តឹងស្នើសុំតុលាការចេញប្រតិវេទន៍ដំណោះស្រាយ និងដីការក្សាការពារ ដូចមានចែងក្នុងផ្នែកទី២ នៃច្បាប់ស្តីពីសិទ្ធិបោះ ឆ្នោត,52U.S.C 10301(“Section 2”), និងមានចែងក្នុងច្បាប់វិសោធនកម្មលើកទី១៤ និង ១៥ នៃរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក ។ តាមរយៈប្រព័ន្ធបោះឆ្នោតដែលខុសច្បាប់របស់ទីក្រុងឡូវែលនេះ ពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេរិកាំងដើមកំណើត អាហ្វ្រិកឡាទីន និងអេស្ប៉ាញ នៅក្នុងទីក្រុងឡូវែលបានបាត់បង់ឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជនដែលខ្លួនពេញចិត្ត ដើម្បីតំណាងពួកគាត់នៅក្នុងសមាជិកក្រុមប្រឹក្សាក្រុង និងនៅក្នុងសមាជិកគណៈកម្មាធិការសាលានៅទីក្រុងឡូវែល ។

**៧-**ការប្រើប្រាស់ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រ សម្រាប់អាសនៈទាំងប្រាំបួននៃសមាជិកក្រុមប្រឹក្សាក្រុងឡូវែល និងអាសនៈទាំងប្រាំមួយនៃសមាជិកគណៈកម្មាធិការសាលាក្រុងឡូវែលបែបនេះ ធ្វើឱ្យបាត់សម្លេងរួមគ្នារបស់ពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិកឡាទីន និងអេស្ប៉ាញក្នុងសាលាក្រុងឡូវែល ។ ជាលទ្ធផលប្រព័ន្ធបោះឆ្នោតដែលបេក្ខជនភាគច្រើនលើសលុបជាជនជាតិស្បែកស និងអ្នកបោះឆ្នោតភាគច្រើនជាជនជាតិស្បែកសបែបនេះ ធ្វើឱ្យដើមបណ្តឹងបាត់បង់សិទ្ធិអំណាចស្មើគ្នាក្នុងដំណើរការបោះឆ្នោត និងរារាំងមិនឱ្យពួកគាត់បោះឆ្នោតជ្រើសរើសបេក្ខជនតាមការពេញចិត្តរបស់ពួកគាត់ ។ ការធ្វើដូច្នេះ គឺជាការរំលោភបំពានដល់ផ្នែកទី២នៃច្បាប់ស្តីពីសិទ្ធិបោះឆ្នោត ។

**៨-**យោងតាមព័ត៌មាន និងជំនឿយ៉ាងហោចណាស់ បើស្រុកណាមួយនៅក្នុងទីក្រុងឡូវែលដែលមានសមាជិកតែមួយរូប ប៉ុន្តែក្នុងស្រុកនោះមានចំនួនពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេិកាំងដើមកំណើតអាហ្វ្រិកឡាទីន និងអេស្ប៉ាញដែលមានអាយុគ្រប់បោះឆ្នោត និងដែលបូកបញ្ចូលគ្នាមានចំនួនច្រើនលើសលុបនៃចំនួនប្រជាជនសរុប គួរបង្កើតឱ្យមានសមាជិកភាពនៃតំណាងជនជាតិភាគតិចទាំងនោះនៅក្នុងក្រុមប្រឹក្សាក្រុងឡូវែល និងក្នុងគណៈកម្មាធិការសាលាក្រុងក្រុងឡូវែល ។

**៩-**យោងតាមកាលៈទេសៈទូទៅ រួមទាំងលក្ខខណ្ឌប្រវត្តិសាស្រ្ត សង្គម សេដ្ឋកិច្ច និងលក្ខខណ្ឌដទៃទៀតនៅក្នុងបរិបទនៃទីក្រុងឡូវែលប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រដែលប្រើ ដើម្បីបោះឆ្នោតជ្រើសរើសតាំងសមាជិកក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលាក្រុងឡូវែលបានរំលោភផ្នែកទី២ នៃច្បាប់ស្តីពីសិទ្ធិបោះឆ្នោត ,52 U.S.C 10301, និងប៉ះពាល់ដល់ប្រការស្តីពីការការពារសិទ្ធិស្មើគ្នានៃច្បាប់វិសោធនកម្មលើកទី១៤ និង១៥នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ។

**១០-**យោងលើសំអាងហេតុទាំងនេះ និងយោងតាមទឡ្ហីករណ៍ខាងក្រោម ដើមបណ្តឹងស្នើសុំប្រតិវេទន៍ដំណោះស្រាយ និងការរក្សាការពារ ដើម្បីហាមឃាត់ការអនុវត្តប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះ ក្នុងដំណើរបោះឆ្នោតជ្រើស តាំងសមាជិកក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលានៃក្រុងឡូវែលតទៅទៀត ។

**លក្ខណៈប្រជាសាស្រ្តនៃទីក្រុងឡូវែល**

**១១-**ទីក្រុងឡូវែលមានប្រវត្តិជាទីក្រុងរបស់ជនអន្តោប្រវេសន៍ ។ ដូច្នេះលក្ខណៈប្រជាសាស្រ្តនៃទីក្រុងនេះ ប្រែប្រួលយ៉ាងច្រើន ។ រយៈពេល៥០ឆ្នាំ ចុងក្រោយនេះ ចំនួនប្រជាពលរដ្ឋដែលមិនមែនជាជនជាតិស្បែកសកើនឡើងយ៉ាងខ្លាំងនៅក្នុងទីក្រុងឡូវែល ។ ពលរដ្ឋជនជាតិភាគតិចទាំងនេះ គឺពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិកឡាទីន និងអេស្ប៉ាញ ។

**១២-**ពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិកឡាទីន និងអេស្ប៉ាញ ជាច្រើនចាប់ផ្តើមផ្លាស់ទីលំនៅមកនៅឡូវែលនៅក្នុងទសវត្សរ៍១៩៦០ ។ កំណើតនេះបន្តកើតមានរហូតដល់ទសវត្សរ៍១៩៨០ និងក្រោយៗមកទៀត ។

មិនខុសពីជនជាតិភាគតិចដទៃទៀត ជនជាតិកូឡុំប៊ីចូលចិត្តធ្វើការតាមរោងចក្រនៅទីក្រុងឡូវែល ។ ក្រុងឡូវែលសព្វថ្ងៃមានជនជាតិព័រតូរីកូ ជនជាតិ ដូមីនិក និងកូឡុំប៊ីជាច្រើន ។

**១៣-**ជនអន្តោប្រវេសន៍អាស៊ីជាច្រើនចាប់ផ្តើមផ្លាស់ប្តូរទីលំនៅមកនៅទីក្រុងឡូវែលនៅទសវត្សរ៍ឆ្នាំ១៩៨០ ។ ភាគច្រើននៃជនអន្តោប្រវេសន៍ និងជនភៀសខ្លួនទាំងនេះ គឺជាជនជាតិខ្មែរមកពីប្រទេសកម្ពុជា និងឡាវជាច្រើនដែលជាអន្តោប្រវេសន៍ដែរ បានផ្លាស់ទីលំនៅមករស់នៅទីក្រុងឡូវែលក្នុងរយៈពេលដូចគ្នានេះ ។ នៅទីក្រុងឡូវែល ក៏សម្បូរជនជាតិអាស៊ីអាគ្នេយ៍ផងដែរ ។

**១៤-**ថ្មីៗនេះ ជនអន្តោប្រវេសន៍អាហ្វ្រិកមានចំនួនកាន់តែច្រើនឡើងបានផ្លាស់ទីលំនៅមករស់នៅទីក្រុងឡូវែល ។ ពួកគាត់មកពីប្រទេសកាម៉េរូន លីបេរីយ៉ា **តទៅទំព័រទី ១៣**

Continued from page 11

## IN THE UNITED STATES DISTRICT...

**6.** Plaintiffs seek declaratory and injunctive relief under Section 2 of the Voting Rights Act, 52 U.S.C. § 10301 (“Section 2”), as well as under the Fourteenth Amendment to theUnited States Constitution and the Fifteenth Amendment to the United States Constitution.

Through Lowell’s unlawful electoral system, Asian-Americans and Hispanics /Latinos in the City of Lowell have been denied an equal opportunity to elect candidates of their choice to the Lowell City Council and Lowell School Committee.

**7.** The use of an exclusively at-large plurality voting system for all nine seats on the Lowell City Council and all six seats on the Lowell School Committee dilutes the combined electoral strength of Asian-Americans and Hispanics/Latinos in the City of Lowell. It results in the election of predominantly white candidates from neighborhoods with the largest percentage of white voters, depriving Plaintiffs of equal voting power and preventing them from electing candidates of their choice in violation of Section 2.

**8.** Under a reasonable and properly-apportioned single-member districting plan, at least one single-member district in Lowell can be created for both the Lowell City Council and the Lowell School Committee in which Asian-Americans and Hispanics/Latinos combined would comprise a majority of the citizen voting age population, voting age population, and total population.

**9.** Under the totality of the circumstances, including the historical, socio-economic, and other conditions that prevail in Lowell, the at-large plurality election system used to elect the Lowell City Council and Lowell School Committee violates Section 2 of the Voting Right Act, 52 U.S.C. § 10301, as well as the Equal Protection Clause of the Fourteenth Amendment of the United States Constitution and the Fifteenth Amendment to the United States Constitution.

**10.** For these reasons, and as further alleged in detail below, Plaintiffs seek, among other things, declaratory judgment and injunctive relief prohibiting the further utilization of an entirely at-large plurality system for electing members of the Lowell City Council and Lowell School Committee.

### JURISDICTION AND VENUE

**11.** This Court has jurisdiction of this action pursuant to 28 U.S.C. § 1343(a), because this action seeks to redress the deprivation, under color of state law, of rights, privileges and immunities secured by the Voting Rights Act; and 28 U.S.C. § 1331, because this action arises under the laws of the United States.

**12.** This Court has jurisdiction to grant both declaratory and injunctive relief, pursuant to 28 U.S.C. §§ 2201 and 2202.

**13.** This Court has personal jurisdiction over the Defendants, all of whom reside in this district.

**14.** Venue is proper in this district pursuant to 28 U.S.C. § 1391(b), because a substantial part of the events or omissions giving rise to the claims herein occurred in this district and because the Defendants reside in this district.

### PARTIES

#### Plaintiffs

**15.** CHANMONY HUOT is an Asian-American Lowell resident and registered voter. As a result of Lowell’s at-large plurality municipal election system, Mr. Huot is denied the equal opportunity to elect candidates of his choice to the Lowell City Council and Lowell School Committee. Mr. Huot resides in the Highlands neighborhood of Lowell.

**16.** VLADIMIR SALDAÑA is a Hispanic/Latino Lowell resident and registered voter. As a result of Lowell’s at-large plurality municipal election system, Mr. Saldaña is denied the equal opportunity to elect candidates of his choice to the Lowell City Council and Lowell School Committee. Mr. Saldaña resides in the Sacred Heart neighborhood of Lowell.

**17.** CHAMPA PANG is an Asian-American Lowell resident and registered voter. As a result of Lowell’s at-large plurality municipal election system, Ms. Pang is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Pang resides in the Acre neighborhood of Lowell.

**18.** LIANNA KUSHI is an Asian-American Lowell resident and registered voter. As a result of Lowell’s at-large plurality municipal election system, Ms. Kushi is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Kushi resides in the Highlands neighborhood of Lowell.

**19.** THOEUN KONG is an Asian-American Lowell resident and registered voter. As a result of Lowell’s at-large plurality municipal election system, Mr. Kong is denied the equal opportunity to elect candidates of his choice to the Lowell City Council and Lowell School Committee. Mr. Kong resides in the Highlands neighborhood of Lowell. **Continued to Page 13**

តមកទំព័រទី ១២ ## ពាក្យបណ្តឹងអំពីសិទ្ធិបោះឆ្នោត...

សេរ៉ាឡេអូន កូឌីវ័រ កេនយ៉ា ហ្គាណា នីហ្សេរីយ៉ា និងតូហ្គោ ។

**១៥-** សព្វថ្ងៃនេះ ជនជាតិភាគតិចមានចំនួនលើសពី៤៩%នៃប្រជាជនសរុបនៅទីក្រុងឡូវែល ។ ក្នុងនោះ ពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិកឡាទីន និងអេស្ប៉ាញ និងពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ីមានប្រហែល៤០% នៃចំនួនប្រជាជនសរុប ។

### ក្រាហ្វិកទី១ ៖ល្បាយប្រជាជននៅទីក្រុងឡូវែល តាមភាគរយនៃចំនួនប្រជាជនសរុបចាប់ពីឆ្នាំ១៩៨០-២០១៥




[2] *សូមមើលឯកសារដដែលត្រង់* 141-160, 173-179

[3] *សូមមើលឯកសារដដែលត្រង់* 181-188

### កង្វះតំណាងនៃជនជាតិភាគតិចនៅទីក្រុងឡូវែល

**១៦-**ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រដែលអនុវត្តទូទៅនៃទីក្រុងឡូវែលធ្វើឱ្យបាត់ឱកាសសម្រាប់ជនជាតិភាគតិចដែលមានសម្លេងស្មើរពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋសរុបនៅក្នុងទីក្រុងឡូវែល ។ ពួកគាត់បាត់បង់ឱកាសក្នុងការរើសតំណាងដែលខ្លួនពេញចិត្តដោយសារប្រព័ន្ធបោះឆ្នោតមិនសមាមាត្រដែលរាំងខ្ទប់សម្លេងជនជាតិភាគតិច ។

**១៧-**ជាឧទាហរណ៍ ទោះបីចំនួនពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិក និងអេស្ប៉ាញបូកបញ្ចូលគ្នាមានរហូតដល់៤០%នៃចំនួនពលរដ្ឋសរុបនៃក្រុងឡូវែលនៅក្នុងសមាជិកក្រុមប្រឹក្សាក្រុងឡូវែល ឬគណៈកម្មាធិការសាលានៃទីក្រុងឡូវែលគ្មានតំណាងណាម្នាក់មកពីសហគមន៏ពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី និងពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិក និងអេស្ប៉ាញនោះទេ ។ ក្នុងចំណោមអាសនៈសមាជិកក្រុមប្រឹក្សាក្រុងឡូវែលទាំង៤៥ក្នុងការបោះឆ្នោត៥អាណត្តិចុងក្រោយនេះ មានតែអាសនៈចំនួនពីរប៉ុណ្ណោះដែលបានទៅពលរដ្ឋអាមេរិកាំងដើមកណើតអាស៊ី ឬពលរដ្ឋអាមេរិកាំងដើមកំណើតអាហ្វ្រិក ឬអេស្ប៉ាញ ។ ក្នុងរយៈពេលដូចគ្នានេះ គ្មានបេក្ខជនពីខាងពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី ឬពលរដ្ឋអាមេរិកាំងដើមកណើតអាហ្វ្រិក និងអេស្ប៉ាញណាម្នាក់ជាប់ឆ្នោតសូម្បីតែមួយកៅអីក្នុងចំណោមអាសនៈទាំង៣០នៃគណៈកម្មាធិការសាលានៃទីក្រុងឡូវែល ។ មិនដែលមានបេក្ខជនពីខាងជនជាតិភាគតិចណាម្នាក់ដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្រុងឡូវែល ឬសមាជិកគណៈកម្មាធិការសាលាក្រុងឡូវែលសូម្បីតែមួយកៅអីក្នុងការបោះឆ្នោតក្រុងប្រាំអាណត្តិចុងក្រោយនេះ ។ ចំនួនជនជាតិដើមភាគតិចបូកបញ្ចូលគ្នាមាន រហូតដល់ជិតពាក់កណ្តាលនៃប្រជាជនសរុបនៅក្នុងទីក្រុងឡូវែលក្នុងពេលបោះឆ្នោតទាំងប្រាំអាណត្តិកន្លងទៅនេះ ។ តួលេខនេះ មានបង្ហាញជូននៅក្នុងក្រាហ្វិកទី ២ និង៣ ខាងក្រោម ។

### ក្រាហ្វិកទី២ ៖តំណាងជនជាតិភាគតិចនៅក្នុងក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលាឆ្នាំ២០០៧-២០១៥




តទៅទំព័រទី ១៤

**Continued from page 12**

## IN THE UNITED STATES DISTRICT...

**20.** DENISSE COLLAZO is a Hispanic/Latino Lowell resident and registered voter. As a result of Lowell's at-large plurality municipal election system, Ms. Collazo is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Collazo resides in the Acre neighborhood of Lowell.

**21.** SUE J. KIM is an Asian-American Lowell resident and registered voter. As a result of Lowell's at-large plurality municipal election system, Ms. Kim is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Kim resides in the Acre/Downtown neighborhood of Lowell.

**22.** SOADY OUCH is an Asian-American Lowell resident and registered voter. As aresult of Lowell's at-large plurality municipal election system, Ms. Ouch is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Ouch resides in the Lower Highlands neighborhood of Lowell.

**23.** TOOCH VAN is an Asian-American Lowell resident and registered voter. As a result of Lowell's at-large plurality municipal election system, Mr. Van is denied the equal opportunity to elect candidates of his choice to the Lowell City Council and Lowell School Committee. Mr. Van resides in the Sacred Heart neighborhood of Lowell

**24.** CARMEN BERMUDEZ is a Hispanic/Latino Lowell resident and registered voter. As a result of Lowell's at-large plurality municipal election system, Ms. Bermudez is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Bermudez resides in the Acre neighborhood of Lowell.

**25.** KEI KAWASHIMA-GINSBERG is an Asian-American Lowell resident and registered voter. As a result of Lowell's at-large plurality municipal election system, Ms. Kawashima-Ginsberg is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Kawashima-Ginsberg resides in the Highlands neighborhood of Lowell.

**26.** DANIEL K. UK is an Asian-American Lowell resident and registered voter. As a result of Lowell's at-large plurality municipal election system, Mr. Uk is denied the equal opportunity to elect candidates of his choice to the Lowell City Council and Lowell School Committee. Mr. Uk resides in the Centerville neighborhood of Lowell.

**27.** FAHMINA ZAMAN is an Asian-American Lowell resident and registered voter.

As a result of Lowell's at-large plurality municipal election system, Ms. Zaman is denied the equal opportunity to elect candidates of her choice to the Lowell City Council and Lowell School Committee. Ms. Zaman resides in the Highlands neighborhood of Lowell.

## Defendants

**28.** Defendant CITY OF LOWELL is a city in the Commonwealth of Massachusetts organized under Massachusetts' Plan E form of government pursuant to Mass. G. L. c. 43, §§ 93- 116.

**29.** Defendant KEVIN J. MURPHY is the appointed City Manager of the City of Lowell. Mr. Murphy is sued in his official capacity.

**30.** Defendant LOWELL CITY COUNCIL is a legislative body and the governing authority of the City of Lowell, Massachusetts. The Lowell City Council is established pursuant to Mass. G. L. c. 43, §§ 95-99 under the Plan E form of government and exercises general and specific legislative powers. Among its duties, the Lowell City Council votes on bond issues, proposed city budgets, financial appropriations, land acquisitions and sales, loans, traffic control issues, and zoning changes. Lowell City Council members are elected biennially by city-wide at-large plurality elections held in odd numbered years. See 1957 Mass. Act. 725 § 2. The Lowell City Council has the power to implement changes to the city's Plan E form of government and to adopt districting plans that comply with the Voting Rights Act and United States Constitution.

**31.** Defendants RITA M. MERCIER, RODNEY M. ELLIOTT, EDWARD J. KENNEDY, JR., JOHN J. LEAHY, WILLIAM SAMARAS, JAMES L. MILINAZZO, DANIEL P. ROURKE, COREY A. BELANGER, and JAMES D. LEARY are members of the Lowell City Council. Each of these Defendants is sued in his or her official capacity.

**32.** Defendant LOWELL SCHOOL COMMITTEE is responsible for the conduct of the public schools for the City of Lowell. See Mass. G. L. c. 43, § 95. The Lowell School Committee members are elected biennially by city-wide at-large plurality elections held in odd numbered years.

**33.** Defendants STEPHEN J. GENDRON, JACQUELINE DOHERTY, CONNIE A. MARTIN, ROBERT J. HOEY, JR., ROBERT JAMES GIGNAC, and ANDRE DESCOTEAUX, are members of the Lowell School Committee. Each of these Defendants is sued in his or her official capacity. **Continued to Page 14**

តមកទំព័រទី ១៣

## ពាក្យបណ្ដឹងអំពីសិទ្ធិបោះឆ្នោត...

**ក្រាហ្វិកទី ៣ ៖តំណាងជនជាតិភាគតិចក្នុងក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលាក្រុងឡូវែលឆ្នាំ២០០៧-២០១៥**




**ប្រៀបធៀបនឹងចំនួនប្រជាជនសរុប**

**១៨-**ភាពខ្វះអ្នកតំណាងពលរដ្ឋអាមេរិកាំង ដើមកំណើតអេស្ប៉ាញ/អាហ្វ្រិកឡាទីន ជាពិសេសក្នុងសមាជិកគណៈកម្មាធិការសាលានៃទីក្រុងឡូវែល គឺធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍របស់សិស្សសាលានៅសាលារដ្ឋនាក្រុងឡូវែលដោយសារតែចំនួនជនជាតិភាគតិចមានច្រើននៅក្នុងតំបន់ទីក្រុង ។ ដូចបានរៀបរាប់លម្អិតខាងក្រោមចំនួនសិស្សនៅទីក្រុងឡូវែលសរុបមាន៣១,៤% មានដើមកំណើតអេស្ប៉ាញ/អាហ្វ្រិកឡាទីន, ២៩% មានដើមកណើតអាស៊ី ២៣% ជនជាតិស្បែកស និង៧,៤% ជនជាតិស្បែកខ្មៅ /អាហ្វ្រិក ។ តួលេខនេះ មានបង្ហាញជូននៅក្នុង ក្រាហ្វិក ទី៤ ។

**ក្រាហ្វិកទី៤ ៖តំណាងជនជាតិភាគ តិចនៅក្នុងគណៈកម្មាធិការសាលាក្រុងឡូវែលប្រៀបធៀបនៅនឹងចំនួនសិស្សសរុបនៅសាលារដ្ឋក្រុងឡូវែល**




5 *សូមមើល* School & District Profiles: Lowell Enrollment Data (2016-2017), Mass. Dep't of Elem. & Second. Educ. (last visited May 3, 2017), *អាចរកបាននៅ* http://profiles.doe.mass.edu/profiles/student.aspx?orgcode=01600000&orgtypecode=5&fycode=2017.

**១៩-**ប្រសិនបើក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលាក្រុងឡូវែលអនុវត្ត តាមប្រព័ន្ធបោះឆ្នោតតាមចំនួនប្រជាជនតាមស្រុកនីមួយៗ ជាជាងយកតាមប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រដូចពេលបច្ចុប្បន្នពលរដ្ឋអាមេរិកាំងដើមកណើតអេស្ប៉ាញ/អាហ្វ្រិកឡាទីន និងពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ីបូកបញ្ចូលគ្នាអាចបង្កើតបានជាចំនួនជនជាតិភាគតិចដែលមានចំនួនច្រើនលើសលុបយ៉ាងហោចណាស់ក៏នៅក្នុងមួយស្រុកដែរ ។ បើប្ដូរប្រព័ន្ធបោះឆ្នោតបច្ចុប្បន្នជនជាតិភាគតិចមានឱកាសច្រើនក្នុងការបោះឆ្នោតជ្រើសរើសតំណាងដែលខ្លួនពេញចិត្ត ដើម្បីតំណាងពួកគាត់នៅក្នុងក្រុមប្រឹក្សាក្រុង និងក្នុងគណៈកម្មាធិការសាលានៃទីក្រុងឡូវែល ។

**២០-**បើមិនប្ដូរប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រដូចសព្វថ្ងៃនេះទេ ពលរដ្ឋអាមេរិកាំងដើមកំណើតអេស្ប៉ាញ/អាហ្វ្រិកឡាទីន និងពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ីនៅតែបាត់បង់ឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោតជ្រើសតំណាងរបស់ខ្លួនក្នុងក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសាលានៃទីក្រុងឡូវែល ។ ពួកគាត់នឹងនៅតែបាត់ឱកាសក្នុងការចូលរួមក្នុងជីវភាពនយោបាយ ។ បញ្ហានេះធ្វើឱ្យរំលោភដល់ផ្នែកទី២នៃច្បាប់ស្ដីពីសិទ្ធិបោះឆ្នោត ॥

Continued from page 13

## IN THE UNITED STATES DISTRICT...

**34.** Defendant LOWELL ELECTION AND CENSUS COMMISSION is responsible for managing and conducting all municipal, state, and federal elections within the City of Lowell.

**35.** Defendants BEVERLY ANTHES, JOSEPH MULLEN, THEL SAR, and THOMAS FR. O'BRIEN, are members of the Lowell Election and Census Commission. Each of these Defendants is sued in his or her official capacity.BACK-GROUND Lowell's Municipal Election System

**36.** By charter, Lowell follows Massachusetts' Plan E form of government under Mass. G. L. c. 43, §§ 93–116.

**37.** There are nine members of the Lowell City Council, and six members of the Lowell School Committee. The Mayor of Lowell, who is elected by and from the City Council members, also sits on the School Committee.

**38.** Lowell residents elect all nine members of the Lowell City Council and all six members of the Lowell School Committee at the same time in biennial elections held in oddnumbered years. Each seat is for a two year term.

**39.** All Lowell City Council and Lowell School Committee candidates are elected atlarge,city-wide, in a plurality voting system. See 1957 Mass. Act. 725 § 2. At the polls, Lowell voters are presented with a list of candidates for both City Council and School Committee, and may vote for up to nine total City Council candidates and six total School Committee candidates.

The top nine and top six vote-getting candidates are elected to the Lowell City Council and Lowell School Committee, respectively.

**40.** Even though the city is currently divided into eleven separate wards, with each ward encompassing three precincts, the city votes as a whole in this at-large, plurality winnertake-all election system, and thus only the top vote-getting candidates across all wards and precincts win seats on the Lowell City Council and Lowell School Committee. Because the city effectively votes as a single entity, a majority bloc of voters can elect all of their preferred candidates to the Lowell City Council and Lowell School Committee. This election system dilutes the voting power of Lowell's Hispanic/Latino and Asian-American communities.

### Lowell Demographics

**41.** Lowell has historically been a city of immigrants, and accordingly has undergone major demographic changes throughout its history. In the last 50 years, Lowell has seen significant growth in its non-white minority populations, particularly its Asian-American and Hispanic/Latino populations.

**42.** Hispanic/Latino immigrants began moving to Lowell in significant numbers in the 1960s—a trend which continued into the 1980s and beyond. Colombians in particular, like many other minorities throughout the city's history, were drawn to work in Lowell's mills. The city currently has large Puerto Rican, Dominican Republic, and Colombian populations.1

**43.** Asian immigrants began moving to Lowell in large numbers in the 1980s. In particular, many immigrants and refugees from Cambodia began arriving in the United States during this time frame and settled in Lowell. Vietnamese and Laotian immigrants moved to Lowell in significant numbers in the same period. Southeast Asians also comprise a significant portion of Lowell's Asian-American population.2

**44.** More recently, increasing numbers African immigrants are moving to the city, coming from countries ranging from Cameroon, Liberia, Sierra Leone, Ivory Coast, Kenya, Ghana, Nigeria, to Togo.3

**45.** Today, minorities constitute over 49% of Lowell's total population, and Hispanics/Latinos and Asian-Americans combined comprise approximately 40% of the total population.

**46.** According to the U.S. Census Bureau's 2011-2015 American Community Survey (the "2015 ACS"), which was published on February 1, 2017, and which contains the most recent demographic estimates available for the City of Lowell: (a) non-Latino whites constitute approximately 50.7% of Lowell's total population, 55.7% of its voting age population, and 61.0% of its citizen voting age population; (b) Asians constitute approximately 21.8% of Lowell's total population, 21.0% of its voting age population, and 17.0% of its citizen voting age population; (c) Hispanics/Latinos constitute approximately 18.1% of Lowell's total population, 15.4% of its voting age population, and 15.5% of its citizen voting age population; and (d) blacks/African Americans constitute approximately 7.1% of Lowell's total population, 6.7% of its voting age population, and 5.3% of its citizen voting age population. The 2015 ACS data for the City of Lowell is summarized in Table 1 below. Similar demographic data from the 2010 Census, the most recent official decennial census, is summarized in Table 2 below.

Table 1 - Lowell Demographics (U.S. Census 2011-2015 American Community Survey)4 **Please Read next Issue**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការិយាល័យវិទ្យុ RFA និង វិទ្យុ VOA ស្ថិតក្រោមការពិនិត្យពិច័យ

**ដោយ ផាន់ ស៊ូមី និង Ben Paviour | ថ្ងៃច័ន្ទ ទី១៤ ខែសីហា ឆ្នាំ២០១៧**

ការិយាល័យវិទ្យុពីរដែលផ្តល់មូលនិធិដោយសហរដ្ឋអាមេរិក រួមជាមួយកាសែតខេមបូឌាដេលី និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផង ស្ថិតក្នុងអ្វីដែលទំនងជាការពង្រីក និងការស៊ើបអង្កេតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសាធារណៈ កាន់តែកើនឡើងពីការបង់ពន្ធរបស់ស្ថាប័នទាំងនេះ ដែលគេដឹងចំពោះទំនាក់ទំនងដ៏តានតឹងជាមួយរដ្ឋាភិបាល។

យោងតាមលិខិតមួយច្បាប់ដែលចុះហត្ថលេខាកាលពីថ្ងៃសុក្រដោយលោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវបានយកមកចុះផ្សាយដោយសារព័ត៌មាន Fresh News ដែលគាំទ្ររដ្ឋាភិបាលនៅថ្ងៃដដែលនោះបានឱ្យដឹងថា វិទ្យុអាស៊ីសេរី (RFA) និងវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) មិនបានចុះបញ្ជីជាមួយនាយកដ្ឋានពន្ធដារទេ ហើយមិនមានអាជ្ញាប័ណ្ណផ្សព្វផ្សាយត្រឹមត្រូវឡើយ។ លិខិតដដែលនេះបានស្នើឱ្យលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានស៊ើបអង្កេតករណីនេះ។

ប៉ុន្តែលោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍កាលពីម្សិលមិញថា លោកមិនទាន់បានទទួលឯកសារនេះនៅឡើយទេ ហើយទំនងជាច្រានចោលការណែនាំរបស់ខ្លួនដោយលើកឡើងថា ប្រព័ន្ធផ្សព្វផ្សាយដែលមានកម្មវិធីវិទ្យុ RFA និង VOA ទេដែលជាអ្នកត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីជាមួយក្រសួងរបស់លោក។

លិខិតនេះធ្វើឡើងបន្ទាប់ពីមានឯកសារដាច់ដោយឡែកមួយផ្ញើពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅកាសែតដេលី មួយសប្តាហ៍មុន ដែលចោទថាកាសែតនេះមិនបានបង់ពន្ធក្នុងទឹកប្រាក់ជាង៦,៣លានដុល្លារ។ ការចោទប្រកាន់នោះត្រូវបានច្រានចោលដោយលោក Bernard Krisher ចាងហ្វាងកាសែតនេះ ដែលនៅក្នុងការឆ្លើយតបកាលពីថ្ងៃពុធលោកបានលើកឡើងថា ការរួមចំណែកសប្បុរសធម៌របស់លោកដែលលោកប៉ាន់ប្រមាណថា មានទឹកប្រាក់ដល់ទៅ៣៩លានដុល្លារនោះ គួរតែពិចារណាបញ្ចូលក្នុងទិន្នន័យរបស់រដ្ឋាភិបាល។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនអាចទាក់ទងសុំការបំភ្លឺបានទេអំពីករណីនេះ។ គេមិនច្បាស់ថា តើវាទាក់ទងទៅនឹងសំណើរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីដើមខែនេះដែលស្នើឱ្យក្រុមមន្ត្រីពិនិត្យការបង់ពន្ធរបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនឬយ៉ាងណានោះឡើយ។

លិខិតរបស់លោក អូន ព័ន្ធមុនីរ័ត្ន ផ្ញើជូនលោក ខៀវ កាញារីទ្ធ មានខ្លឹមសារថា ការប្រើប្រាស់ទិន្នន័យដែលផ្តល់ដោយក្រសួងព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រកឃើញថា ស្ថានីយវិទ្យុ និងស្ថានីយទូរទស្សន៍មួយចំនួនបានអនុវត្តតាមច្បាប់ពន្ធដារ ដោយមានការលើកលែងគួរឱ្យកត់សម្គាល់ពីវិទ្យុ RFA និង VOA។

លោក អូន ព័ន្ធមុនីរ័ត្ន បានសរសេរថា ការិយាល័យវិទ្យុទាំងពីរនេះ "បាន និងកំពុងធ្វើសកម្មភាពយកព័ត៌មាន និងផ្សព្វផ្សាយតាមរយៈការជួលម៉ោងនៅស្ថានីយវិទ្យុឯកជនមួយចំនួនក្នុងការចាក់ផ្សាយបន្តដោយមិនបានបំពេញកាតព្វកិច្ចចុះបញ្ជីពន្ធដារឡើយ បើទោះជាមានការអញ្ជើញ និងជូនដំណឹងពីអគ្គនាយកដ្ឋានពន្ធដាររួចហើយក្តី"។ លោកបានបន្ថែមថា "ដោយសារកិច្ចសហប្រតិបត្តិការរបស់វិទ្យុអាស៊ីសេរី និងវិទ្យុ VOA នេះត្រូវស្ថិតនៅក្រោមសមត្ថកិច្ចនៃការចុះបញ្ជី ឬការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងត្រួតពិនិត្យរបស់ក្រសួងព័ត៌មាន សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងជំរុញឱ្យវិទ្យុទាំងពីរនេះផ្តល់កិច្ចសហការ ឬបើពុំនោះសោត សូមឯកឧត្តមមេត្តាចាត់វិធានការតឹងរ៉ឹងចាំបាច់ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមានចំពោះវិទ្យុទាំងពីរនេះ"។

លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍កាលពីម្សិលមិញថា លោកកំពុងតែធ្វើដំណើរ ហើយមិនទទួលបានលិខិតនេះទេ។ នៅពេលសួរថាតើវិទ្យុ RFA និង VOA ត្រូវចុះបញ្ជីជាមួយក្រសួងព័ត៌មានឬយ៉ាងណានោះ លោក ខៀវ កាញារីទ្ធ បានឆ្លើយតបថា "ស្ថានីយវិទ្យុដែលបានលក់ម៉ោងផ្សាយឱ្យពួកគេចាំបាច់ត្រូវ" ហើយលោកមិនបានឆ្លើយតបចំពោះសំណួរបន្ថែមឡើយ។ ស្ថានីយក្នុងស្រុកមួយចំនួននឹងត្រូវជាប់ពាក់ព័ន្ធក្នុងការផ្តល់ម៉ោងផ្សាយ។

អ្នកនាំពាក្យវិទ្យុ RFA និង VOA ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកមិនអាចទាក់ទងសុំការបំភ្លឺបានទេ។ វិទ្យុ RFA និង VOA ត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលអាមេរិក ហើយតែងតែប្រកាន់ជំហររិះគន់លើរដ្ឋាភិបាលកម្ពុជាបង្កឱ្យមានការចោទប្រកាន់ពីសំណាក់មន្ត្រីគណបក្សប្រជាជនកម្ពុជាមួយចំនួនថា ការិយាល័យផ្សព្វផ្សាយនេះគឺជាយន្តការឃោសនាក្នុងន័យបង្កើតឱ្យមានបដិវត្តន៍។

កាសែតខេមបូឌាដេលី ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ ដោយលោក Bernard Krisher ដែលមានដើមកំណើតអាមេរិក និងជាអតីតអ្នកសារព័ត៌មានមានមូលដ្ឋាននៅទីក្រុងតូក្យូបានក្លាយជាសប្បុរសជន។

នៅក្នុងការឆ្លើយតបរបស់លោកផ្ញើជូនលោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីថ្ងៃពុធ លោក Bernard Krisher បានបង្ហាញពីការរួមចំណែករបស់លោកតាមរយៈអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរដែលលោកលើកឡើងថា បានសាងសង់សាលារៀន៥៦១ខ្នង គិតជាទឹកប្រាក់ប្រមាណ៣៩លានដុល្លារព្រមទាំងកាសែតដេលី ផង ដែលលោកហៅថា ជា "សហគ្រាសសង្គម" សំដៅបណ្តុះបណ្តាលអ្នកសារព័ត៌មានកម្ពុជា និងផ្តល់ព័ត៌មានត្រឹមត្រូវផងដែរ។

លោកបានសរសេរនៅក្នុងលិខិតមួយច្បាប់អមដោយអ៊ីម៉ែលភ្ជាប់មកជាមួយដោយមានច្បាប់ចម្លងមូលប្បទានបត្រកាលពីពេលថ្មីៗដែលបានបង់ទៅឱ្យក្រសួងអប់រំដែលមូលប្បទានបត្រនីមួយៗមានទឹកប្រាក់រាប់ម៉ឺនដុល្លារឯណោះថា "តាំងពីពេលចាប់ផ្តើមមក ខ្ញុំមិនដែលយកប្រាក់ខែ ហើយក៏មិនដែលចំណេញពីកាសែតខេមបូឌាដេលីដែរ"។ លោកបានបន្ថែមថា "រាល់កម្រៃទាំងអស់ចំណាយទៅលើសាលារៀនទាំងនោះ"។

លោកបានសរសេរថា "កាសែតខេមបូឌា ដេលី និងរូបខ្ញុំបានរួមចំណែកយ៉ាងច្រើនក្នុងការគាំទ្រដល់តម្រូវការជាតិកម្ពុជា។ ទាំងនេះគួរតែត្រូវបានសរសើរ។ ខ្ញុំជំទាស់ការដែលថា ខ្ញុំជំពាក់អគ្គនាយកដ្ឋានពន្ធដារនូវទឹកប្រាក់២៥.៧៥៦.០១៥.៦៩៥ រៀល"។

លោកស្រី Deborah Krisher-Steel ចាងហ្វាងរងកាសែតនេះ និងជាកូនស្រីរបស់លោក Bernard Krisher បានមានប្រសាសន៍កាលពីសប្តាហ៍មុនថា លោកស្រីបានទិញទ្រព្យសកម្មមួយចំនួននៃទ្រព្យសកម្មរបស់កាសែតដេលី ពីឪពុករបស់លោកស្រី ហើយបានបញ្ចូលទ្រព្យសកម្មនោះជាអាជីវកម្មថ្មីកាលពីដើមឆ្នាំនេះ។

លោក ប៉ា ងួនទៀង ប្រធានមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានមានប្រសាសន៍ថា លោកដឹងថា គ្មានច្បាប់ណាតម្រូវឱ្យវិទ្យុ VOA និង RFA ចុះបញ្ជីជាមួយក្រសួងណាមួយឡើយ ហើយបានសួរពីការកំណត់ពេលចាត់វិធានការលើប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាល។

លោកបានថ្លែងថា កម្មវិធីវិទ្យុទាំងពីរនេះបានផ្សព្វផ្សាយក្នុងប្រទេសកម្ពុជាច្រើនឆ្នាំមកហើយ។ ខ្ញុំបារម្ភថា វាដល់ពេលចេញលិខិតទាំងនេះពីព្រោះវាដល់ពេលសម្រាប់ការបោះឆ្នោតសាកលនៅឆ្នាំក្រោយ។ ពួកគេព្យាយាមដាក់សម្ពាធថ្មី"៕

**សារុន**

តមកពីទំព័រទី ១២

## សម្ភាសន៍លោក ជន លីហ៊ី សមាជិក...

វ៉ាស្នា នួន ជា "ខងសីល័រ" ដូចគ្នាយើងធ្វើការបានល្អជាមួយគ្នាតែនៅពេល វ៉ាស្នា នួន មានបញ្ហាពីផ្ទះសម្បែងរបស់ខ្លួន ហើយ "ឡូសាន់" បានសរសេររឿងនេះឡើងបានធ្វើឱ្យ វ៉ាស្នា នួន បាត់បង់សម្លេងឆ្នោតរបស់ខ្លួន ពីព្រោះជាតំណាងគេ មិនអាចឱ្យមានរឿងយ៉ាងនេះកើតឡើងបានទេ...

**សូបិន ពិនៈ** ត្រឡប់មកករណីបេក្ខជននៃជនជាតិភាគតិច វ៉ាស្នា នួន កាលពីអាណត្តិមុនបើទោះបីជាធ្លាប់មានរៀងពីមុនមកក៏ដោយ ក៏ វ៉ាស្នា នួន បានឈ្នះឆ្នោតស្ទើរតែគ្រប់សង្កាត់ទាំងអស់... ឈ្នះបានលេខ១នៅ១៤សង្កាត់ ក្នុងចំណោមសង្កាត់៣០ មានតែសង្កាត់ "បែលវើឌៀ" មួយទេប៉ុន្តែក៏មិនបានជាប់ឆ្នោត... នេះគឺជាករណីដែលជាដើមហេតុនៃបណ្តឹងជាភាពអយុត្តិធម៌ដែលគេថាវាផ្ទុយនឹងទស្សនៈនៃរដ្ឋធម្មនុញ្ញ...ពីព្រោះថា "បែលវីឌៀ" ចង់ឱ្យនរណាជាប់ក៏ជាប់ ចង់ឱ្យនរណាធ្លាក់ក៏បានដែរ...

**ជន លីហ៊ីៈ** ខ្ញុំដឹងតែប៉ុណ្ណេះថា វ៉ាស្នា នួន បានសម្លេងឆ្នោតច្រើន តែមិនចាំថាដោយសារតែ "បែលវីឌៀ" ទើបចាញ់ឆ្នោតទៅវិញនោះទេ...

**សូបិន ពិនៈ** ខ្ញុំនៅចងចាំថា មានការពិភក្សាច្រើនពីរឿងនេះ ឌីក ហាវ បានលើកឡើងពីរឿងនេះ ក្នុងប្លុករបស់លោក ហើយពិសេសទៅទៀតក៏បានក្លាយទៅជារឿងសហរដ្ឋថា ជា "រឿងអាស្រូវនៅម៉ាសឈូសិត" ទៅហើយ...

**ជន លីហ៊ីៈ** ខ្ញុំមិនបានចាំចំនួនជាលទ្ធផលនៃការបោះឆ្នោតពេលនោះ បានច្បាស់លាស់ទេ...

**សូបិន ពិនៈ** លោកធ្វើ "ខងសីល័រ" បានប៉ុន្មានឆ្នាំហើយ? ហើយមានបំណងធ្វើទៅមុខប៉ុន្មានឆ្នាំទៀត?

**ជន លីហ៊ីៈ** ៥ឆ្នាំហើយ! បន្ទាប់ពីធ្វើនៅគណកម្មការសាលារៀន១០ឆ្នាំ ដូច្នេះខ្ញុំនៅ៥ឆ្នាំទៀតឱ្យគ្រប់១០ឆ្នាំប៉ុណ្ណឹងបានហើយ! ឪពុករបស់ខ្ញុំ ក៏បានធ្វើ១០ឆ្នាំដូចគ្នាដែរ...

**សូបិន ពិន ៈ** ខ្មែរផុសស.រ.អា: សូមអរគុណលោក ជន លីហ៊ី...។

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ក្រុមហ៊ុនសហរដ្ឋអាមេរិកផ្តល់ពិន្ទុខុសៗគ្នាចំពោះបរិយាកាសធុរកិច្ចនៅក្នុងប្រទេសកម្ពុជា

**ដោយ** BEN PAVIOUR | **ថ្ងៃព្រហស្បតិ៍ ទី១៧ ខែសីហា ឆ្នាំ២០១៧**

យោងតាមការស្ទាបស្ទង់មតិថ្មីមួយបានឱ្យដឹងថា ក្រុមហ៊ុនសហរដ្ឋអាមេរិកដែលកំពុងធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាមានសុទិដ្ឋិនិយមចំពោះបរិយាកាសវិនិយោគជាទូទៅនៅក្នុងប្រទេសនេះ ប៉ុន្តែនៅមានការមិនពេញចិត្តចំពោះអំពើពុករលួយរចនាសម្ព័ន្ធពន្ធដារ និងឥរិយាបថចំពោះសហរដ្ឋអាមេរិក ហើយអ្វីដែលជាបញ្ហាមិនពេញចិត្តមួយទៀតនោះ គឺពិបាករកកម្មករជំនាញដែលស៊ីថ្លៃថោក។

ធ្វើឡើងដោយសភាពាណិជ្ជកម្មសហរដ្ឋអាមេរិកកាលពីឆ្នាំមុននិងចេញនៅដើមខែនេះ ការស្ទាបស្ទង់មតិទស្សនវិស័យធុរកិច្ចអាស៊ានឆ្នាំ២០១៧ (២០១៧ Asean Business Outlook Survey) ប្រមូលចម្លើយពីសមាជិកចំនួន២៦ក្នុងចំណោមសមាជិកចំនួន៩៨នៃក្រុមប្រឹក្សាធុរកិច្ចកម្ពុជា-អាមេរិក ហៅថា AmCham ដែលឆ្លើយតបនឹងការស្ទាបស្ទង់តាមអ៊ីនធឺណិត។

ការយល់ឃើញដែលតែងតែមានទំនោរទុទិដ្ឋិនិយមចំពោះបរិយាកាសធុរកិច្ចនៅកម្ពុជាគាំទ្រលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់សន្ទស្សន៍? ទំនុកចិត្តធុរកិច្ច (Business Confidence Index) ធ្វើឡើងដោយធនាគារ ANZ Royal ដែលចេញកាលពីខែមីនា និងដែលគូសបញ្ជាក់ថាមានការធ្លាក់ចុះពិន្ទុ៧ភាគរយនៅក្នុងទំនុកចិត្តធុរកិច្ច ដោយមួយផ្នែកបណ្តាលមកពីអស្ថិរភាពនយោបាយ។

ក្រុមហ៊ុនទាំងអស់ដែលត្រូវបានស្ទាបស្ទង់ដោយ AmCham កាលពីមេសា និងខែឧសភាឆ្នាំមុនរំពឹងថា នឹងបន្ថែមបុគ្គលិក ឬរក្សាបុគ្គលិកក្នុងកម្រិតដដែលកាលពីឆ្នាំមុន រីឯជិត២ភាគ៣លើកឡើងថា ពួកគេរំពឹងថា នឹងពង្រីកទីតាំងរបស់ខ្លួន ហើយចំនួន៨៨ភាគរយលើកឡើងថា ពួកគេរំពឹងរកប្រាក់ចំណេញក្នុងឆ្នាំ២០១៦បានប្រសើរជាងឆ្នាំមុន២០១៥។

ហើយ៦៩ភាគរយនៃសមាជិក AmCham បានលើកឡើងថា បរិយាកាសធុរកិច្ចក្នុងស្រុកជាទូទៅមានភាពប្រសើរឡើង បើធៀបនឹង៤៥ភាគរយនៅទូទាំងតំបន់អាស៊ាន។

ទោះជាយ៉ាងណា លទ្ធផលនៃការស្រាវជ្រាវផ្សេងៗទៀតមិនសូវល្អនោះទេ។ អ្នកឆ្លើយមិនសូវពេញចិត្តដូចឆ្នាំ២០១១ បើនិយាយទាក់ទិននឹងកត្តាទាំង១៦ដែលត្រូវបានធ្វើការស្ទាបស្ទង់ រាប់ចាប់ពីកត្តាអាចទទួលបានកម្លាំងពលកម្មចំណាយអស់ទាប រហូតដល់ឥរិយាបថចំពោះសហរដ្ឋអាមេរិក។ កត្តាទាំងពីរនេះធ្លាក់ចុះប្រហែល១ភាគ៣ចាប់តាំងពី៥ឆ្នាំមុនមកដោយកត្តាចុងក្រោយទទួលបានពិន្ទុទាបគ្រប់ពេលត្រឹមតែ២៧ភាគរយ។ សមាជិក AmCham ក៏មាន៥៤ភាគរយទំនងជាលើកឡើងថា ពួកគេកំពុងធ្វើប្រតិបត្តិការនៅក្នុង "ប្រព័ន្ធបរិយាកាស-នយោបាយ និងក្រោមរដ្ឋាភិបាលដ៏មានស្ថិរភាព" ផងដែរ។

មានតែអ្នកឆ្លើយត្រឹមតែ៤ភាគរយប៉ុណ្ណោះដែលលើកឡើងថា ពួកគេពេញចិត្តកម្រិតនៃអំពើពុករលួយនាពេលបច្ចុប្បន្ន ហើយតិចជាង២០ភាគរយលើកឡើងថា ពួកគេពេញចិត្តចំពោះកត្តាធុរកិច្ចភាគច្រើនផ្សេងៗទៀត រួមមានច្បាប់ និងបទបញ្ជាផ្ទៃក្នុងហេដ្ឋារចនាសម្ព័ន្ធនិងការងាយរកបានវត្ថុធាតុដើមជាដើម។

លទ្ធផលទាំងនេះខុសគ្នាស្រឡះពីប្រទេសវៀតណាមដែលការស្ទាបស្ទង់ភាគច្រើនមានស្ថិរភាព ឬក៏កើនឡើងពីឆ្នាំ២០១១ ដោយសមាជិកអាស៊ានភាគច្រើនផ្សេងទៀតមានលទ្ធផលចម្រុះ។

លោក Bretton Sciaroni ប្រធាន AmCham មិនបានឆ្លើយតបនឹងសំណើសុំធ្វើអត្ថាធិប្បាយទេ។

ប៉ុន្តែការស្ទាបស្ទង់មតិរបស់ធនាគារ ANZ Royal លើកឡើងថា ក្រុមហ៊ុននៅកម្ពុជាកំពុងប្រឈមនឹងបញ្ហាប្រឈមថ្មី ដោយគូសបញ្ជាក់ថា ពិន្ទុទំនុកចិត្តធុរកិច្ចនៅកម្ពុជាដែលទទួលបាន៧៦ពិន្ទុលើ១០០នោះគឺជាពិន្ទុទាបបំផុតមិនធ្លាប់មានចាប់តាំងពីឆ្នាំ២០១៤មក នេះបើយោងតាមកាសែតភ្នំពេញប៉ុស្តិ៍។

ក្រុមហ៊ុនខ្នាតតូច និងមធ្យមទំនងជាមិនសូវមានទំនុកចិត្ត រីឯក្រុមហ៊ុនខ្នាតធំផ្តល់ពិន្ទុស្រដៀងគ្នាទៅនឹងឆ្នាំមុននោះ។

របាយការណ៍នេះមានខ្លឹមសារថា "ការធ្លាក់ចុះទំនុកចិត្តជាទូទៅអាចកើតចេញពីការកើនឡើងនៃការប្រកួតប្រជែងនៅក្នុងទីផ្សារ អស្ថិរភាពនយោបាយ និងភាពមិនច្បាស់លាស់នៃការបោះឆ្នោតនាពេលខាងមុខដោយរារាំងក្រុមហ៊ុនមិនឱ្យវិនិយោគក្នុងពេលឆាប់ៗ"។

អំពើពុករលួយ កង្វះហេដ្ឋារចនាសម្ព័ន្ធ និងការចំណាយខ្ពស់លើថ្លៃទឹកភ្លើងសុទ្ធតែត្រូវបានម្ចាស់ក្រុមហ៊ុនក្នុងស្រុកចាត់ទុកថាជាឧបសគ្គរាំងស្ទះ នេះបើយោងតាមកាសែតភ្នំពេញប៉ុស្តិ៍ ខណៈអ្នកឆ្លើយបានលើកសរសើរដល់ការខិតខំប្រឹងប្រែងប្រមូលពន្ធដែលមានភាពប្រសើរឡើង និងការចំណាយទាបលើកម្លាំងពលកម្ម។

លោក មាស សុខសេនសាន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថា លោកមិនទាន់បានឃើញការស្ទាបស្ទង់មតិរបស់ AmCham នៅឡើយទេ ប៉ុន្តែ បានទទួលស្គាល់ថា មាន "បញ្ហាមួយចំនួនដែលចាំបាច់ត្រូវធ្វើកំណែទម្រង់"។

ប៉ុន្តែលោកបានលើកឡើងថា អ្នកឆ្លើយហាក់បីដូចជាមើលរំលងកិច្ចខិតខំប្រឹងប្រែងដ៏វិជ្ជមានរបស់រដ្ឋាភិបាល រួមមានការខំប្រឹងប្រែងប្រមូលពន្ធច្រកចេញចូលតែមួយ និងការធ្វើឱ្យការចុះបញ្ជីពាណិជ្ជកម្មកាន់តែមានភាពងាយស្រួល។ លោកបានថ្លែងថា "ខ្ញុំអត់ដឹងទេថា តើគេមានបានពិចារណាលើកត្តាទាំងអស់នេះឬក៏អត់នោះ"។

លោក Miguel Chanco អ្នកវិភាគឈានមុខគេក្នុងតំបន់នៅ Economist Intelligence Unit បានលើកឡើងថា ការធ្លាក់ចុះពិន្ទុនៅកម្ពុជាមានបុព្វហេតុច្បាស់លាស់។

លោកបានសរសេរក្នុងអ៊ីម៉ែលមួយថា "ស្ថានភាពចលាចលដែលកើតឡើងក្រោយការបោះឆ្នោតជាតិឆ្នាំ២០១៣ដ៏ចម្រូងចម្រាស និងយុទ្ធនាការបង្ក្រាបផ្នែកនយោបាយកំពុងបន្តរបស់គណបក្សប្រជាជនកម្ពុជាចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៥មកច្បាស់ណាស់ថា សុទ្ធតែជាកត្តាជះឥទ្ធិពលលើបរិយាកាសនយោបាយនៅក្នុងប្រទេសនេះ"។

លោកបានលើកឡើងទៀតថា ប្រាក់ខែគោលដំឡើងក្រោយការបោះឆ្នោតមិនស្របតាមសង្វាក់ផលិតកម្ម និងអតិផរណាទេ រីឯអំពើពុករលួយនៅតែកើតមានបន្ទាប់ពីមានការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយក្នុងឆ្នាំ២០១០។

លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា ជាទូទៅកម្ពុជានៅតែមានចំណុចវិជ្ជមានដោយសារការវិនិយោគគ្មានបញ្ហានោះទេ ហើយបញ្ហាពិបាកដោះស្រាយនៅក្នុងប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ានបន្តធ្វើឱ្យប្រទេសនេះមើលទៅអំណោយផលសម្រាប់ការវិនិយោគរយៈពេលវែង"៕ **ស៊ុយឈាង**



# តំបន់មាត់ឃ្លង់ក្នុងរដូវវស្សាក្លាយ
# ជាកន្លែងគួរឱ្យចាប់អារម្មណ៍គ្រប់ទិសទី







**ដោយ : យ៉ាន់ ចាន់ថេត**

**ខេត្តត្បូងឃ្មុំ :** "ភូមិនេសាទ" ស្ថិតនៅតំបន់ស្ពានមាត់ឃ្លង់ ឃុំជីរោទ៍ទី២ ស្រុកត្បូងឃ្មុំក្នុងរដូវទឹកទន្លេមេគង្គឡើងក្លាយទៅជាកន្លែងទេសចរណ៍ដោយមានអ្នកទេសចរពីគ្រប់ទិសទីទៅលេងកម្សាន្ត។ អ្នកទេសចរជិះអាចកង់ទឹកកម្សាន្តស្ងួចត្រី និងខ្លះទៀតនាំគ្នាទទួលទានអាហារនៅតាមកន្លែងលក់ដូរ ។ អ្នកទេសចរទៅលេងកម្សាន្តច្រើននៅថ្ងៃសៅរ៍ និងអាទិត្យ ។

ស្ត្រីអ្នកលក់ដូរម្នាក់ឈ្មោះ វ៉ាត សំបូរ អាយុ ៤៥ឆ្នាំ រស់នៅភូមិទួលវិហារ ឃុំជីរោទ៍ទី២ ប្រាប់ឱ្យដឹងកាលពីពេលថ្មីៗកន្លងថា ប្តីរបស់គាត់ដែលពិការជើងម្ខាងតែងតែចេញទៅរាយមងនៅតាមបឹងផ្នែកខាងលើត្រង់ស្ពានមាត់ឃ្លង់ ថ្ងៃខ្លះបានរហូតដល់ជិត១០គីឡូក្រាម ។ ត្រីទាំងនោះគាត់លក់បាន១គីឡូក្រាមតម្លៃជាង១ម៉ឺនរៀល។ អ្នកដំណើរ និងអ្នកទេសចរតែងតែឈប់ម៉ូតូ និងរថយន្តចូលទិញត្រីយកទៅធ្វើម្ហូប ។

ក្រៅពីលក់ត្រីអ្នកស្រី វ៉ាត សំបូរ ជួយ

**តទៅទំព័រទី២៣**




## តម្រឹមធ្មេញដោយមិនយកថ្លៃ

ប្រសិនបើលោកអ្នកឬគ្រួសារ មានអាយុ២១ឆ្នាំ ឬក្មេងជាង សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ ដើម្បីរកមើលថាតើលោកអ្នកមានសិទ្ធនឹងទទួលបាននូវ "ប្រដាប់តម្រឹមធ្មេញ"ដោយ មិនចំណាយប្រាក់ ឬទេនៅពេលលោកអ្នកមាន"ម៉ាសហ៊ែល"? លោកអ្នកអាចនឹងទទួលសំណងរហូតដល់៤,៣០០ដុល្លា សម្រាប់ដាក់"ប្រដាប់តម្រឹមធ្មេញ"ទៅតាមសេចក្តីត្រូវការរបស់អ្នក។

The BRACES PLACE

វេជ្ជបណ្ឌិត មូហាប់ វីសកាឡា DDS MSD

## តើយើងធ្វើអ្វីខ្លះ?

ដាក់ធ្មេញដោយដែក * ដោយមាស * ដោយ"អិនវីសាឡាញ" * ដោយចាន

## អ្វីដែលធ្វើឱ្យយើងប្រសើរជាននោះ?

- ឆ្លុះមើលបន្ថែម នឹង ជួបគ្រូពេទ្យ
- យើងទទួលយក"ម៉ាសហ៊ែល" នឹង "អិនស្វូរិន"ផ្សេងៗទៀត
- បង់ប្រាក់កក់មុនតិចបំផុត នឹងមានវិធីបង់ប្រាក់រំលោះប្រចាំខែសម្រាប់អ្នកដែលគ្មាន"អិនស្វូរិន" សូមទូរស័ព្ទ ឬក៏មកកន្លែងដែលស្រួលរករបស់យើង

710 Chelmsford St. Lowell, MA 01851

**(978)- 454 - 0774** (មានអ្នកនិយាយភាសាខ្មែរ)

ដើម្បីបានព័ត៌មានបន្ថែម, សូមចូលទៅ"វេបសាយ"យើង: www.bracesplaces.com

## រឿងប្រលោមលោក

# រឿង ចៅពិន



**នាអំឡុងឆ្នាំ១៩៥០-៦០ តើមានអ្វីកើតឡើងនៅក្នុងជីវភាពគ្រួសារខ្មែរ!** ដោយ ខ្មែរផុសស.រ.អា

**តពីលេខមុន**

នាំពូសាយមកដល់គាត់ទៅថ្វាយបង្គំលោក រួចហើយក៏នាំចៅពិនចេញទៅទាំងមិនបានលាចៅថាចស្រួលបួលផង បានត្រឹមតែលើកដៃជាសញ្ញាលាគ្នាតែប៉ុណ្ណោះ។ មកដល់ផ្ទះចៅពិនសប្បាយចិត្តណាស់ដោយបានជួនម្តាយតែគ្រាន់តែជំរាបសួរឪពុកជាធម្មតាតែប៉ុណ្ណោះ, គេនិយាយប្រាប់ម្តាយនៅរឿងរ៉ាវជាច្រើនមានរឿងចាំពូសាយត្រូវទៅយកតែមិនឃើញមានរឿងធ្វើបុណ្យខ្មោចមានរឿងមុសខាំជាំពេញដៃ...តែមិននិយាយរឿងចៅថាចទេ ពីព្រោះតែបានសន្យាគ្នារួចហើយ...គាប់ជួនជាចំថ្ងៃសៅរ៍នឹងអាទិត្យចៅពីនបាននៅផ្ទះ២ថ្ងៃ មុននឹងត្រឡប់ទៅវត្តវិញនាព្រឹកថ្ងៃចន្ទ។ លើកនេះចៅពិនបានដឹងពីឪពុកថា"ខ្លួននឹងបានចូលរៀននៅបវេស្សនកាលខាងមុខនេះហើយ" ហើយមុននឹងត្រឡប់ទៅវត្តវិញថ្ងៃចន្ទនេះ ត្រូវត្រៀមជាមួយនឹងម្តាយរៀបចំឱ្យមានមុង មានកន្ទេល មានក្រម៉ា នឹងខោអាវសម្រាប់ផ្លាស់ប្តូរ ក្រែងពូសាយមិនបានទៅទទួលម្តងទៀតហើយដោយសារតែមានបទពិសោធន៍ដ៏កំសត់នៅវត្តនេះហើយ បានបង្រៀនចៅពិនឱ្យចេះត្រៀមឥវ៉ាន់ផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ពេលអាសន្ន ហើយដោយសារតែនៅវត្តនោះឯងដែលចៅពិនមកផ្ទះវិញសូត្រធមិជាមួយម្តាយឱ្យរូគ្នានអាក់ទៀតផង ធ្វើឱ្យម្តាយមានអំនួត ចំពោះចំណេះថ្មីរបស់កូនប្រុសខ្លួនជាអាណែក។

ថ្ងៃចន្ទព្រឹកមកដល់មុនត្រឡប់ទៅវត្តវិញចៅពិនបានទៅរើសពងទា ដែលចិញ្ចឹមប្រមាណ ៤-៥គូរ ជាមួយបងស្រី យ៉ាស៊ុន មកជូនម្តាយបាន២ដងដៃរួស្រស់ស្រូបបបរជាមួយពងទាប្រៃពេលព្រឹករួចហើយ ក៏សំពះលាម្តាយចេញទៅជាមួយពូសាយដោយមាន "កាតាបដាក់ឥវ៉ាន់ប្រើប្រាស់តូចមួយទៅជាមួយផង ទៅឡើងរថយន្ត "ហ្សីប" ទាហ៊ានដែលចតនៅមុខការិយាល័យលោកកុម៉ងដង់ម៉ាំងជាឪពុក, សំពះលាឪពុករួចហើយក៏ចេញដំណើរសំដៅទៅវត្តថ្មី ដោយឆ្លងស្ពានដែក នាទឹកស្ទឹងកំពុងឡើងយ៉ាងល្អក់រ៉ំល់, កាត់ផ្សារកំពង់ស្ពឺ ឆ្លងស្ពានថ្មមួយទៀតនៅខាងជើងកំពង់ស្ពឺ កាត់តាមរការធំរួចបានទៅដល់វត្តដែលនៅខាងស្តាំផ្លូវជាតិ ។ លោកគ្រូសូម៉េតចៅអធិការចាំចៅពិនរួចជាស្រេច ដើម្បីចេញទៅបិណ្ឌបាត្រដូចសព្វមួយដង។

ដល់ពេលចេញដំណើរជាមួយលោកគ្រូល្ហម ដើម្បីទៅបិណ្ឌបាត្រ។ មិនដូចចៅពិនដែលបានទៅផ្ទះម្តងម្កាលចៅថាចមិនបានទៅផ្ទះទេ គេរីករាយណាស់ដោយបានចៅពិនត្រឡប់មកដល់វត្តមកវិញ ទាំង២នាក់ហាក់ដូចជាត្រូវគ្នាខ្លាំងណាស់។



ឆែកែវ និងស៊ីក្លូ នៅមានប្រើខ្លះៗនៅរាជធានីនាឆ្នាំ១៩៥០ នៅក្រៅក្រុង និងជនបទមានឡានឈ្នួល រឺម៉ក រទេះសេះ និងរទេះគោ

នៅវត្តថ្មីមានកូនសិស្សជិទង់១២-៣នាក់ដែរ ដែលមករស់ជាកូនសិស្សលោកនៅហូបបាយវត្តបំពេញកិច្ចការក្នុងវត្តនៅថ្ងៃឈប់សម្រាក ឬក៏ពេលចេញពីរៀន តែពួកគេទៅរៀននៅសាលាបឋមសិក្សាឯកណ្តាលទីរួមខែត្រ ដែលកំពង់ស្ពឺមិនមានសាលាខ្ពស់ជាងនេះទេ, លោកកុម្មងដង់ម៉ាំង កាលពីនៅពេលរៀនចប់ក៏រឹតថ្នាក់បញ្ចប់បឋមសិក្សា (Courssuperieur) គឺត្រូវប្រឡងយកសញ្ញាប័ត្របញ្ចប់បឋមសិក្សា(Certificat) នោះ រួចក៏ទៅប្រឡងចូលរៀនសាលានាយទាហ៊ាន (Ecole des officiersactif) នៅភ្នំពេញសិស្សទាំងអស់ដែលបានរៀនចប់(សែរទីហ្វិកា) ត្រូវទៅរៀននៅក្រុងភ្នំពេញហើយ បើមិនចូច្នោះ ទេគេតែប្រឡងចូលទៅធ្វើការរដ្ឋបាលធំៗបានហើយ ។ ចៅថាចនឹងចៅពិនមិនទាន់បានចូលរៀនទេ ម្លោះហើយបានតែរត់លេងរៀនសូត្រធមិ ធ្វើឱ្យឪពុកម្តាយសប្បាយចិត្តណាស់ទៅហើយ ក្រៅពីនោះរង់ចាំតែលោកគ្រូហៅប្រើតែប៉ុណ្ណោះ ហើយមាតាបិតាអ្នកទាំងពីរ ក៏រង់ចាំពីការអប់រំនៅវត្ត គឺការចេះរស់ដោយខ្លួនឯងការចេះស្តាប់បំរើចាស់ទុំ នឹងរៀនសូត្រធមិឱ្យបានច្រើនតែប៉ុណ្ណោះ។

នៅពេលលោកគ្រូត្រឡប់ពីបិណ្ឌបាត្រវិញ មានយុវជនជានិស្សិតម្នាក់បានមករង់ចាំថ្វាយបង្គំលោកគ្រូរួចជាស្រេច, លោកគ្រូសម្តែងសេចក្តីត្រេកអរនឹងបានជួបនិស្សិតម្នាក់នោះ ។ គេជាអតីតកូនសិស្សលោកនៅវត្តយើងនេះដែលបានចេញទៅសិក្សាឯទីក្រុងភ្នំពេញច្រើនឆ្នាំហើយ គេបានត្រឡប់មកផ្ទះដែលនៅជនបទដាច់ស្រយ៉ាលម្នាក់នោះឈ្មោះសុផាន់ដោយគេត្រូវចូលមកសម្រាកនៅវត្តមួយយប់សិនមុននឹងបន្តដំណើរពីព្រលឹមអុរទៅស្រុកលោកគ្រូសួរថា :

-អាត្មាអរណាស់ បានចៅឯងមកលេង! មើល្បចៅឯងចេញទៅរៀននៅភ្នំពេញច្រើនឆ្នាំហើយ ឥឡូវដល់ថ្នាក់ណាហើយ?

-កូណាលោកគ្រូ ខ្ញុំកូណានឹងបញ្ចប់ថ្នាក់បរិញ្ញាខាងច្បាប់ចុងឆ្នាំនេះហើយ រួចហើយបានអាហារូបករណ៏ទៅរៀនឯស្រុកបារាំងបីឆ្នាំថែមទៀត, ឥឡូវនេះខ្ញុំកូណាចូលមកថ្វាយបង្គំលាលោកគ្រូ រួចទៅលាម៉ែនឹងពុកនៅឯស្រុកទៀត, ខ្ញុំកូណានឹងចេញទៅស្រុកព្រឹកស្អែកនេះ ហើយ!

-រៀនបានខ្ពស់ណាស់ហ្ន! ពេលណាទៅទើបរៀបចប់? ហើយទៅបារាំងទៅទេម្នាក់ឯងទេឬ?

-កូណាទៅស្រុកបារាំង ទៅតែម្នាក់ឯងទេ ទៅរៀនបន្ថែម៣ឆ្នាំទៀត...ខ្ញុំកូណាសូមអរព្រះគុណលោកគ្រូណាស់ ដែលបានទទួលឱ្យខ្ញុំកូណានៅវត្តរហូតដល់បានរៀនចប់សាលាបឋមសិក្សាបន្ទាប់មក នៅឯភ្នំពេញក៏ទៅសុំសំណាក់នៅវត្តឧណ្ណាលោម បានមួយឆ្នាំក៏បានសុំបួក (អាហារូបករណ៏) ទៅស្នាក់អាស្រ័យក្នុងសាលាស៊ីសុវត្ថិរហូតដល់រៀនចប់លីសេ(វិទ្យាល័យ) អស់៦ឆ្នាំទៀត... ឆ្នាំបន្តមកទៀតខ្ញុំកូណាចេញមកសុំបង្រៀនសាលាឯកជនយកកម្រៃសម្រាប់ទៅរៀនសាលាច្បាប់បន្តទៅទៀតផង ហេតុនេះហើយបានជាខ្ញុំកូណារវល់ពេកមិនដែលមានពេលមកថ្វាយបង្គំលោកគ្រូទាល់តែសោះហើយពុកនឹងម៉ែក៏មិនសូវបានជួបគ្នាដែរ លើកក្រោយនេះនឹងបែកគ្នាយូរទៀត ដោយខ្ញុំកូណាត្រូវទៅបន្តវិជ្ជាខាងច្បាប់នៅឯស្រុកបារាំង នៅ២-៣ខែខាងមុខនេះ ហេតុនេះហើយបានជាខ្ញុំកូណាមកកំពង់ស្ពឺនេះឱ្យហើយ បន្តិចទៀតនឹងរវល់ខ្លាំងមិនបានមកទៀតទេ...

-ឱចៅអើយ ឯងរៀនពូកែរណាស់ អាត្មាអរជំនួសសំណាងឪពុកម្តាយឯងណាស់...រៀនបានច្រើនអីចឹង ដូច្នេះនិយាយបារាំងបានច្រើន ហើយមែនទេ?...តើមាននរណាខ្លះជួយណែនាំចៅដែរទេ?

-កូណា លោកគ្រូ ចាប់ពីថ្នាក់ទី៦ទៅគេរៀនបារាំងទាំងអស់គ្មានវិញ្ញាសាខ្មែរទៀតទេ... ដូច្នេះសិស្សទាំងអស់គេនិយាយបារាំងសរសេរបារាំងបានច្បាស់លាស់តាំងពីថ្នាក់ទី៦ទៅហើយ... មានសិស្សច្បងដែលគេរៀនមុនៗ ឥឡូវក្លាយជាបញ្ញាវន្តនយោបាយគេជួយណែនាំយើងច្រើន ដូចជាលោក សឺង ង៉ុកថាន់ ជាសិស្សសាលាច្បាប់ពីមុនមានលោក ឌុក រ៉ាស៊ី លោក ស៊ុម វ៉ា អ្នកនយោបាយល្បីៗទាំងនោះ យកចិត្តទុកដាក់នឹងសិស្សប្អូនគេណាស់...

-អើ គេឃើញយើងជាសិស្សក្រីក្រ មកពីស្រុកស្រែចំការផតប្រកែរប្រកាន់យើងនោះវាប្រសើរណាស់ទៅហើយ...លោកគ្រូតបដោយឃើញថាអ្នកធំជាច្រើន មានចរិកជាអ្នកខ្ពស់មើលងាយអ្នកក្រធ្វើឱ្យអាចារ្យៗនឹងកូនសិស្សលោកដែលអង្គុយជុំចាំស្តាប់ការឆ្លើយឆ្លងដ៏ពិរោះនេះ ឡើងច្របរមាត់...

-កូណា អ្នកធំដែលបានរៀនសូត្រច្រើនៗ តែស្លូតបូតចេះជួយយកអាសារគេឯងណាស់លោកគ្រូ! សុផានតបវិញ។

-អាត្មាជូនពរឱ្យឯងធ្វើដំណើរឱ្យបានសុខសប្បាយ ហើយរៀនចប់ឆាប់ត្រឡប់មកជួយជាតិវិញណា... លោកគ្រូសង្ឃដីការហើយ ក៏និមន្តបន្តរកាងារទៀតទៅ...រីឯសុផានក៏ទៅរកកុដិលោកគ្រូសូត្រដែលខ្លួនធ្លាប់នៅបំរើលោកពីក្មេងៗ ដើម្បីសម្រាកមួយរាត្រីមុននឹងបន្តដំណើរនាព្រហ៊ាមស្រាងៗ តាមរថយន្តឈ្នួលបន្តរពេញមួយថ្ងៃទៅភូមិកំណើតខ្លួនទៀត។

ចៅពិននៅដក់អារម្មណ៏លើព្រឹត្តិការជាមួយសុផាន យ៉ាងជ្រាលជ្រៅ ពីព្រោះយុវជននោះរៀនដល់ថ្នាក់មន្ត្រីធំរៀនបានខ្ពស់ជាងឪពុករបស់ខ្លួនទៅទៀត តែមកដេកនៅវត្តមិនដូចមន្ត្រីស៊ីវិលឬទាហ៊ានរបស់រាជការដែលមានឋានន្តរសក្តិធំ មានផ្ទះក៏ធំ គេមិនដេកនៅវត្តទេ ពិសេសទៅទៀតនោះ

**តទៅលេខក្រោយ**

Job Title : **DEPUTY SHERIFF**
Job Title : ADMINISTRATOR STATE EQUAL OPPORTUNITY PROGRAMS
Department : DEPARTMENT OF ADMINISTRATION
Division : The Office of Diversity, Equity and Opportunity
Opening Date/Time : Thu. 08/17/17 12:00 AM Eastern Time
Closing Date/Time : Wed. 09/13/17 11:59 PM Eastern Time
Salary : $37.95 - $43.02 Hourly
$69,076.00 - $78,305.00 Annually
Pay Grade : 134A
Job Type : Non-Union (99)
Bargaining Union : Non-Union (99)
Location : One Capitol Hill, Providence, Rhode Island
Scheduled Work Days ; Hours of Work Unclassified; Standard : Monday-Friday; 8:30 am-4:00 pm
Work Week : Non-Standard
Assignment(s)/Comments : POSITION REPOSTED--Previous Applicants Need Not Reapply.
Job # : 2466-10003-1

**GENERAL STATEMENT OF DUTIES:** To plan, organize, direct and evaluate the work of a staff engaged in assuring compliance with the requirements of all federal and state laws and regulations regarding equal opportunity; to provide training and technical assistance as is necessary for all state departments to comply with equal opportunity laws and regulations; and to do related work as required.

SUPERVISION RECEIVED: Works under the administrative direction of the Personnel Administrator with wide latitude for the exercise of independent judgement; work is reviewed upon completion, through conferences and submitted reports, for results obtained and conformance to statewide policies and objectives, laws, rules and regulations.

SUPERVISION EXERCISED: Plans, directs, coordinates, supervises and evaluates the work of a monitoring technical assistance and clerical staff engaged in carrying out a comprehensive Affirmative Action and Equal Opportunity Program.

***Illustrative Examples of Work Performed:***

To plan, coordinate, organize, evaluate and direct a program designed to assure compliance with the requirements of all federal and state laws and regulations regarding equal opportunity and to work closely with the state and federal agencies concerned with equal opportunity.

To provide training and technical assistance as is necessary for all state departments to comply with equal opportunity laws and regulations.

To coordinate and evaluate the state and departmental Affirmative Action Plans and to recommend changes in order to improve the performance of these plans.

To consult with the various appointing authorities in the state to familiarize them with the aims of the equal opportunity program and to gain their cooperation in attaining these goals.

To prepare reports for the Governor as to the progress and status of the State's Equal Opportunity Program.

To act as an advisor in regard to the screening, examination and hiring of job applicants in order to assure that the process is not discriminatory against anyone because of race, color, religion, sex, age, national origin or physical or mental handicap.

To participate in the development and implementation of programs for training, education, job redesign, and career counseling to assure opportunities for upward mobility of employees.

To establish contact with women's and minority groups in order to understand the problems facing them in seeking State employment and to work with these groups in solving the problems.

To be responsible for following national and state legislation and interpreting their provisions concerning equal opportunity programs and their enforcement.

To do related work as required.

***Required Qualifications for Appointment:***

KNOWLEDGES, SKILLS AND CAPACITIES: A thorough knowledge of the principles, practices, and techniques of equal opportunity work and the ability to apply this knowledge to the problems of realizing equal opportunity in state government; a thorough knowledge of the causes and effects of discriminatory practices against minorities and women; a working knowledge of the federal and state laws and regulations as they relate to equal opportunity; a working knowledge of the state personnel system with regard to hiring, training, and promoting; a working knowledge of the organizational structure of State government; the ability to devise programs designed to assure equal opportunities within state government; the ability to maintain effective working relationships with officials, workers and with women's and minority groups; and related capacities and abilities.

EDUCATION AND EXPERIENCE:

Education: Such as may have been gained through: graduation from a college of recognized standing with specialization in Psychology, Sociology, Education, Public Administration, Business Administration, or closely related field; and

Experience: Such as may have been gained through: employment in a responsible supervisory position in a State agency involving responsibility for supervising a staff engaged in a program designed to provide affirmative action and equal opportunity for deprived or minority groups.

Or, any combination of education and experience that shall be substantially equivalent to the above education and experience.




# NOTICE OF PUBLIC MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet at 2:30 P.M. on August 23, 2017 at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, Lowell, MA. The NMMPO will take action on draft TIP Amendment 3 to the FFY 2017-2021 Transportation Improvement Program (TIP), which includes programming of funding for I-495/Route 4 Bridge and intersection improvements in Chelmsford and two intersections along VFW Highway in Lowell. The full agenda can be found at www.nmcog.org. Please note that the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The MPO's public participation process satisfies the LRTA's public participation requirements for the program of projects.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance, free of charge, upon request (including, but not limited to, interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

# សេចក្តីជូនដំណឹងស្តីពីការរៀបចំកិច្ចប្រជុំជាសាធារណៈ

អង្គភាពរៀបចំក្រុង ន័សធន មុីដូលសិច ហៅកាត់ NMMPO នឹងរៀបចំកិច្ចប្រជុំជាសាធារណៈមួយនៅម៉ោង២:៣០នាទី រសៀល ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៧នៅការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន មុីដូលសិច ដែលមានទីតាំងស្ថិតនៅផ្លូវ 40Church Street, Suite 200, Lowell, MA។ ក្នុងជុំនួបនេះ អង្គភាព NMMPO នឹងធ្វើការអនុវត្តន៍ពង្រៀងកែប្រែលើកទី៣ ចំពោះគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ២០១៧-២០២១ ដែលរួមមានកម្មវិធីនៃការផ្តល់មូលនិធិសម្រាប់ការស្តាឡើងវិញនៃផ្លូវចំនុចប្រសព្វ និងស្ពានលេខ 4/I-49%នៅឆេមហ្វិត ហើយនឹងផ្លូវចំណុចប្រសព្វពីរផ្សេងទៀតតាមបណ្តោយផ្លូវហាយវេ VFW ក្នុងក្រុងឡូវែល។ លោកអ្នកអាចទទួលបានព័ត៌មានពីរបៀបវីរៈនៃកិច្ចប្រជុំនេះទាំងស្រុងដោយគ្រាន់តែចូលទៅកាន់វេបសាយ www.nmcog.org នេះ។ សូមបញ្ជាក់ថា ក្នុងគម្រោង TIP នេះ ក៏មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើនសម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA) ផងដែរ។ ដំណើរការចូលរួមជាសាធាណៈរបស់អង្គភាពរៀបចំក្រុងនេះ គឺវាស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន។

**កំណត់ចំណាំ:** ទីតាំងនៃការរៀបចំកិច្ចប្រជុំនេះ ងាយស្រួលសម្រាប់ឱ្យជនពិការចេញចូល និងនៅជិតនិងចំណតឡានក្រុង។ អង្គភាព NMMPO មានទីតាំងសុវត្ថិភាពសម្រាប់ចំណតកង់ដែលស្ថិតនៅជាន់ទី២ ។ សម្រាប់ជុំនួបនេះ NMMPO ក៏ផ្តល់ផងដែរនូវការស្នាក់នៅដ៏សមរម្យ និង,រឺជំនួយផ្នែកភាសាដោយមិនគិតថ្លៃ ប្រសិនបើមានការស្នើរសុំ( មានដូចជាអ្នកបកប្រែជាភាសាអង់គ្លេស និងភាសាផ្សេងទៀត, បកប្រែភាសាដោយមើល រឺស្តាប់តាមរយៈវីដេអូសម្រាប់អ្នកពិការភ្នែក និងថ្លង់, ឧបករណ៏បកប្រែជាសម្លេងសម្រាប់អ្នកគរថ្លង់ និងជនពិការភ្នែក ព្រមទាំងការចែកជូនឯកសារផ្សេងទៀតបតាមដែលមាន ។ សម្រាប់ការចូលរួមរបស់លោកអ្នក និងជំនួយបន្ថែម សូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរស័ព្ទ (978) 454-8021, ខេត ១២១រឺអុីមែលទៅកាន់jhoward@nmcog.org. រាល់ការស្នើរសុំជំនួយនានា ដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីងាយស្រួលក្នុងការរៀបចំ ៕

# លទ្ធផលអាចជួយនឹងគំនិតដែលចង់បាន


លីម គិមយ៉ា

**តំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិ នៅខេត្តកំពង់ធំ**

ពេលថ្មីៗនេះមានសំណើររបស់អតីតឧបនាយករដ្ឋមន្ត្រី និងជាមន្ត្រីជាន់ខ្ពស់គណបក្សហ៊្វុនស៊ិនប៉ិច លោក លឺ ឡាយស្រេងបានផ្ញើលិខិតចំហពីរច្បាប់មួយទៅលោក ហ៊ុន សែន និងមួយទៀតទៅលោក កឹម សុខា ដើម្បីឱ្យមេដឹកនាំគណបក្សមានអាសនៈទាំងពីរស្នើទៅរដ្ឋសភាបង្កើតច្បាប់ការពារនាយករដ្ឋមន្ត្រីផុតអាណត្តិឱ្យមានអភ័យឯកសិទ្ធិនិងដំឡើងគោរមងារជាវីរបុរសជាតិដើម្បីជាការលើកទឹកចិត្តចំពោះគុណបំណាច់ក្នុងការដឹកនាំប្រទេសជាតិ។

ហើយជាមួយគ្នានេះ អតីតប្រធានគណបក្សសង្គ្រោះជាតិលោក សម រង្ស៊ី ក៏គាំទ្រដែរ ព្រមទាំងនិយាយថា : "ឱ៎លោក ហ៊ុន សែន ខ្លួនឯងផ្ទាល់បានស្នើថា បើគណបក្សសង្គ្រោះជាតិស្នើច្បាប់បែបហ្នឹងឱ្យពនាក់ដែលជាមេដឹកនាំកំពូលនៃគណបក្សកាន់អំណាចបានរួចខ្លួនកុំឱ្យមានការយកទោសពៃរ៍អ្វីនៅពេលមានការផ្ទេរអំណាចមកគណបក្សសង្គ្រោះជាតិពេលនោះគណបក្សប្រជាជនកម្ពុជានឹងគាំទ្រ ប៉ុន្តែឱ្យគណបក្សប្រជាជនកម្ពុជា ស្នើខ្លួនឯងវាមិនល្អមើល"។

នៅក្នុងកម្មវិធីផ្សាយទូរទស្សន៍អាស៊ីសេរីកាលពីយប់ថ្ងៃទី១៩ ខែកក្កដា លោក សម រង្ស៊ី ថ្លែងថា : "ក្នុងចិត្តក្នុងគំនិតរបស់យើង គឺយើងគួរតែធ្វើ ទោះជាឥឡូវនេះមានអ្នកខ្លះអៀនខ្មាស់បដិសេធក្តី។ នេះជារឿងរបស់គាត់ទេ តែបើរឿងប្រទេសជាតិយើងឱ្យការផ្ទេរអំណាចនិងដំណើរការប្រជាធិបតេយ្យរលូនទៅមុខគឺយើងត្រូវតែមានច្បាប់បែបហ្នឹងមែន"។

តែនៅប្រទេសអាមេរិកដែលជាប្រទេសប្រជាធិបតេយ្យ គេអាចកាត់ទោស ឬដកចេញពីដំណែងប្រធានាធិបតីនៅពេលកាន់អំណាចបើប្រសិនណាជាមានកំហុស ។ ឯចំណែកប្រទេសបារាំងវិញ បើប្រធានាធិបតីមានកំហុសនៅមុន ឬនៅពេលមានអំណាច គេមិនទាន់យកទៅវិនិច្ឆ័យទេ តែគេចាំឱ្យផុតអាណត្តិសិនបានជាតុលាការហៅទៅដោយមូលហេតុថា កុំឱ្យរំខានដល់កិច្ចការរបស់ប្រធានាធិបតី។ តើមានប្រទេសកាន់លទ្ធិប្រជាធិបតេយ្យណាដែលមានច្បាប់ជូនអភ័យឯកសិទ្ធិដល់អ្នកកាន់អំណាចមួយជីវិត?

បើប្រសិនណាជាមានច្បាប់នេះមែន គឺបានសេចក្តីថា យើងយល់ព្រមឱ្យអ្នកកាន់អំណាចនៅពីលើច្បាប់ដែលយើងទាំងអស់កំពុងតែស្រែកនិងចោទប្រកាន់ថា គណបក្សប្រជាជនកាន់អំណាចផ្តាច់ការ និងមិនគោរពច្បាប់ ។ បើយើងប្រគល់អភ័យឯកសិទ្ធិដល់អ្នកកាន់អំណាចមួយជីវិតនោះមន្ត្រីរាជការទាំងអស់ក៏មានដែរ ពីព្រោះពួកអស់នេះយកលេសថាធ្វើតាមបញ្ជាពីលើមក ។ ហើយចំឡើយអស់នេះនឹងមានជាបន្តបន្ទាប់របៀបគ្នា ។ ទីបញ្ចប់ប្រទេសខ្មែរនឹងមិនទៅជាយ៉ាងណាទេ !។

ពេលនេះ ច្បាស់ជាគេសួរថា ធ្វើយ៉ាងដូចម្តេចឱ្យដំណោះស្រាយការផ្ទេរអំណាចទៅរួចទៅអនាគតក្រោយលទ្ធផលបោះឆ្នោត?

សំនួរនេះជាការត្រឹមត្រូវ ហើយចំឡើយ គឺទៅតាមបរិបទច្រើននៅក្នុងសង្គម និងអ្នកដឹកនាំផ្សេងៗ ។

**ទី១** គឺការទុកចិត្តគ្នាទៅវិញ ទៅមករវាងអ្នកដឹកនាំ ។ ក៏ប៉ុន្តែអ្នកដឹកនាំខ្លះមិនដែលគោរពសំដីរបស់ខ្លួននោះទេ គឺនិយាយឱ្យរួចតែពីមាត់ ហើយគ្មានសិលធម៌ដែលបណ្តាលឱ្យមានវិបត្តិក្នុងសង្គម និងនយោបាយរហូតមកដល់សព្វថ្ងៃនេះ ។

**ទី ២** គឺរចនាសម្ព័ន្ធរបស់ស្ថាប័នរដ្ឋឱ្យមានភាពអព្យាក្រិដ្ឋ និងឯករាជភាព ចំពោះអំណាចនយោបាយ ។

**ទី ៣** គឺប្រជាពលរដ្ឋមិនគាំទ្រអ្នកដឹកនាំណាដែលប្រើអំពើហឹង្សា ដោយចូលរួមដៃមិនគោរពតាមលទ្ធផលពីឆន្ទៈប្រជាពលរដ្ឋ។

**ទី ៤** គឺអ្នកដឹកនាំត្រូវយល់ដឹងថា បើខ្លួនមិនព្រមផ្ទេរអំណាចទេ ខ្លួនមិនអាចរស់រាន្តកាន់អំណាចបានតទៅទៀតទេ ពីព្រោះប្រទេសខ្មែរមិនមែនរស់នៅឯកកោម្នាក់ឯងនោះទេ ។

ប្រសិនបើច្បាប់នេះមានមែននោះ តែគ្មានការទុកចិត្តគ្នាទៅវិញទៅមក ក៏មិនបានការអ្វីដែរ។

ហេតុនេះ គួរតែអ្នកដឹកនាំប្រែចិត្តគំនិតឱ្យមានភាពទុកចិត្តគ្នាទៅវិញ ទៅមកជៀសវាងមានគំនិត " មានអញអត់ឯង មានឯងអត់អញ " គំនិតនេះហើយដែលបណ្តាលឱ្យមានវិបត្តិនៅក្នុងសង្គម និងនយោបាយ។ ព្រមទាំងឱ្យមានចរិតខ្ពង់ខ្ពស់គោរពគ្នាទៅវិញ ទៅមកដោយមិនប្រឌិតនិយាយមួលបង្កាត់ឱ្យឈឺចាប់ដែលយើងធ្លាប់ឃើញមានពីមុនមកហើយ ៕

**លិម គិម យ៉ា**


## កាសែតដែលបំរើសហគមន៏ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់ នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ

**KhmerPost USA, LLC**

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម **Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

ការីនិពន្ធ Staff Writers:

អ្នកនិពន្ធកិត្តិយស **Contributing Writers:**

Richard Howe Jr,

ច្នៃសោភ័ណភាពកាសែត **Design Artist**

Heng Chhunleng

ជំនួយការរដ្ឋបាល Office Coordnator

Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA



**ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស**

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៏
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**



**ហាងនំដូណាត់នៅថេនេសស៊ី**

ទីតាំងនៅផ្លូវកែវដែលមានមនុស្សច្រើនអាគារដាច់តែឯង

ហាងនំតែមួយគត់នៅក្នុងក្រុងមានការបណ្តុះបណ្តាល

**(626) 377-6167**

# អាកប្បកិរិយាចំនួន ១៣ ដែលឪពុកម្ដាយត្រូវជាសវាងចំពោះកូន

**ប្រែសម្រួលដោយខ្មែរផុស ស.រ.អា**

ដូចយើងដឹងហើយថា ឪពុកអ្នកម្ដាយ គឺមានច្រើនប្រភេទ និងចិញ្ចឹមកូនខុសៗគ្នាដោយឪពុកអ្នកម្ដាយខ្លះគឺមានការតឹងរឹងខ្លាំង និងគ្រប់គ្រងរាល់ការងារនៃជីវិតរបស់កូន តែមួយចំនួនទៀតគឺមានការធូរលង់ និងឱ្យកូនធ្វើការសម្រេចចិត្ត និងប្រព្រឹត្ត ហើយរៀនពីកំហុសដោយខ្លួនឯង។ បើទោះបីជាមានវិធីសាស្ត្រជាច្រើនក្នុងការមើលការខុសត្រូវកូនយ៉ាងណាក៏ដោយ គ្រប់ឪពុកអ្នកម្ដាយទាំងអស់គឺចង់ធ្វើអ្វីៗឱ្យបានល្អបំផុតសម្រាប់កូន។

មិនមានវិធីសាស្ត្រដែលត្រឹមត្រូវ ឬខុសក្នុងការចិញ្ចឹមកូននោះទេ តែអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថាមាតាបិតាមួយចំនួនខតខានមិនបានធ្វើជាអ្នកគាំទ្រ និងជាគំរូល្អសម្រាប់កូនៗនោះទេ។ ប្រាកដណាស់ គ្រប់អាណាព្យាបាលទាំងអស់ប្រព្រឹត្តកំហុសឆ្គងម្ដងម្កាល តែមានកំហុសខ្លះគឺវាអាចធំជាងកំហុសផ្សេងទៀត ហើយវាអាចធ្វើឱ្យមានការប៉ះពេលដល់កូនៗ។ ដូច្នេះដើម្បីជៀសវាងកំហុសឆ្គង់អាកប្បកិរិយាចំនួន១៣ខាងក្រោមនេះដែលឪពុកអ្នកម្ដាយគួរតែជៀសវាងៈ

**១). មិនបានបង្កើតឱ្យមានបរិយាកាសសុវត្ថិភាព និងការគាំទ្រដល់កូន**

ឪពុកម្ដាយមួយចំនួនជឿថាការការបង្រៀនកូនឱ្យស្គាល់ពិភពពិតខាងក្រៅ គឺជាមេរៀនដ៏ល្អដែលអាចឱ្យកូនកាន់តែមានឯករាជ។ ប៉ុន្តែវាក៏អាចធ្វើឱ្យកូនមានបញ្ហាការក្នុងការប្ដេជ្ញាចិត្តដើម្បីប្រឈមនឹងសង្គមខាងក្រៅ និងកង្វះទំនាក់ទំនងជិតស្និទ្ធជាមួយឪពុកម្ដាយពេលក្រោយ។ វិធីនៃការបង្រៀនកូននេះ មិនមែនជាការខុសឆ្គងនោះទេ តែវាមិនមែនជាវិធីសាស្ត្រតែមួយប៉ុណ្ណោះទេ។ ការពិតគឺ ថាយើងទាំងអស់គ្នាត្រូវការការយកចិត្តទុកដាក់ និងសេចក្ដីស្រឡាញ់ ដូច្នេះយើងគួរបង្កើតឱ្យមានបរិយាកាសស្និតស្នាលដើម្បីបណ្ដុះនូវសេចក្ដី ស្រឡាញ់ចំពោះកូន។

**២). រិះគន់គ្រប់ទង្វើរបស់កូន**

ការរិះគន់ដោយអវិជ្ជមានចំពោះទង្វើរបស់កូនអាចធ្វើឱ្យកូនគ្មាននូវទំនុកចិត្ត និងការជំរុញទឹកចិត្តការក្នុងការធ្វើនូវអ្វីដែលថ្មី។ ការរិះគន់ពីកំហុសកូនមិនមែនជាវិធីប្រសើរនោះទេ។ ឪពុកម្ដាយគួរយល់ថា វាជារឿងធម្មតាសម្រាប់កូនដែលប្រព្រឹត្តកំហុស ហើយរៀនសូត្រពីកំហុសទាំងនោះ។ មាតិបិតាគួរថ្លឹងថ្លែងរវាងមតិយោបល់វិជ្ជមាននិងអវិជ្ជមាន និងលើកទឹកចិត្តកូនៗកុំឱ្យពួក គេបាក់ទឹកចិត្ត។




**៣). ទាមទារការយកចិត្តទុកដាក់ខ្លាំងពីកូន**

ឪពុកម្ដាយខ្លះ ទាមទារឱ្យកូនយកចិត្តទុកដាក់មកលើខ្លួន ដោយសារមាតាបិតាតែងតែគិតថាកូនៗជំពាក់ពួកគេដោយសារពួកគេចំណាយពេល និងថាមពលច្រើនក្នុងការចិញ្ចឹមបីបាច់ថែរក្សារ។ មាតាបិតា មិនបានយល់ កូនៗគេមានជីវិតផ្ទាល់ខ្លួនរបស់ពួកគេហើយអាចមិនមានពេលវេលាគ្រប់ពេលមកយកចិត្តទុកដាក់ឪពុកម្ដាយនោះទេ។ ដូច្នេះអ្វីដែលល្អបំផុតដែលឪពុកម្ដាយត្រូវធ្វើ គឺផ្ដល់ឱ្យកូននូវពេលវេលាផ្ទាល់ខ្លួនខ្លះ ហើយពេលណាមួយកូនៗនឹងងាកមកចាប់អារម្មណ៍មកលើអ្នកវិញដោយខ្លួនឯង។ គ្មានទំនាក់ទំនងណាអាចបង្ខំបានឡើយ។

**៤). និយាយលេងបែបបង្អាប់ រឺចំអក**

ការដែលនិយាយលេងបែបជាការបង្អាប់ដោយទឹកមុខញញឹមចំពោះកូនអាចធ្វើឱ្យពួកគេមានការបាក់ទឹកចិត្ត និងបាត់បង់ការស្រលាញ់ចំពោះខ្លួនឯង។ ក្នុងនាមជាមាតាបិតាមិនត្រូវនិយាយបែបចំអកដាក់កូន ដោយសារតែរូបរាងខាងក្រៅ រឺអាកប្បកិរិយារបស់ពួកគេ។ វិធីដែលល្អនោះគឺឪពុកម្ដាយគួរនិយាយជាមួយកូនជាលក្ខណៈឯកជនរឺជជែកបែបមនុស្សចាស់ទុំ។

**៥). បន្ទោសរាល់សកម្មភាពរបស់កូន**

ឪពុកម្ដាយខ្លះទំលាក់កុំហុសទៅកូនៗនូវទង្វើមិនល្អដែលឪពុកម្ដាយបានធ្វើចំពោះកូនទៅវិញ បើទោះបីជាមិនមែនជាកុំហុសរបស់កូនក៏ដោយ។

**៦). មិនអនុញ្ញាតឱ្យកូនបញ្ចេញនូវគំនិតនិងអារម្មណ៍**

កាលលាក់បាំងនូវអារម្មណ៏ទាំងអស់ក្នុងចិត្តអាចនាំឆ្ពុះទៅរកការបាក់ទឹកចិត្តនិងឯកា។ ចាំបាច់ណាស់ដែលត្រូវនិយាយចេញពីអារម្មណ៏ទាំងអស់ និងមិនត្រូវលាក់បាំងអារម្មណ៏អវិជ្ជមានក្នុងចិត្តនោះទេ។ ការនិយាយចេញមកនេះ អាចការពារជុំងឺផ្លូវចិត្ត និងរាងកាយរបស់កូន។ ដូច្នេះឪពុកម្ដាយត្រូវលើកទឹកចិត្តកូនឱ្យនិយាយពីអារម្មណ៏របស់ពួកគេ។

**៧). ធ្វើឱ្យកូនមានការភ័យខ្លាច**

ឪពុកម្ដាយមួយចំនួន ធ្វើឱ្យកូនមានការភ័យខ្លាចចំពោះខ្លួន ដែលនាំឱ្យកូនៗមិនហ៊ាននិយាយចេញអ្វីទាំងអស់ និងអាចធ្វើឱ្យទំនាក់ទំនាក់មានការខ្លាតឆ្ងាយពីគ្នាកាន់តែឆ្ងាយឡើងៗ។ វាមានការខុសគ្នារខ្លាំងរវាងការគោរព និងការខ្លាចមាតាបិតា។ ចំាបាច់ណាស់ដែលត្រូវបង្កើតបរិយាកាសស្និតស្នាល និងសេចក្ដីស្រឡាញ់ ដើម្បីធ្វើឱ្យកូនមានអារម្មណ៏និយាយជាមួយឪពុកម្ដាយសម្រាប់ទទួលបាននូវដំបូន្មានល្អៗ។

**៨). គិតតែពីគំនិតខ្លួនឯង**

មាតាបិតាទាំងអស់ គួរតែទទួលយកនូវគំនិត និងមតិយោបល់របស់កូន។ ជាការពិតណាស់ឪពុកម្ដាយ មានការវៃឆ្លាត និងដឹងថា អ្វីដែលល្អបំផុត។ តែចាំបាច់ត្រូវរួមបញ្ចូលគំនិតគ្រួសារទាំងមូលទៅក្នុងដំណើរនៃការធ្វើការសម្រេចចិត្តលើអ្វីមួយគឺជាការប្រសើរ។

**៩). ចង់ឱ្យកូនបំពេញនូវក្ដីស្រមៃរបស់ខ្លួន**

វាជារឿងអាត្មានិយមដែលចង់ឱ្យកូនធ្វើអ្វីៗទៅតាមឪពុកម្ដាយចង់ឱ្យធ្វើនោះ។ កូនម្នាក់ៗគឺមានការគិត, ការយល់ឃើញ និងពិភពលោករបស់គេរៀងៗខ្លួន។ ដូច្នេះ គួរតែឱ្យកូនធ្វើការសម្រេចចិត្តដោយខ្លួនឯង បើមិនដូច្នោះទេ គ្មាននរណាម្នាក់ក្នុងចំណោមអ្នក និងកូនទទួលបានភាពរីករាយនោះទេ។

**១០). គ្រប់គ្រងកូនដោយលុយកាក់ និងរបស់របរ**

ឪពុកម្ដាយមិនគួររំពឹងទុកថានឹងទទួលបានអ្វីមួយពីកូនត្រឡប់មកវិញនៅពេលផ្ដល់ឱ្យកូននូវអំណោយ ឬលុយកាក់។ ក្នុងនាមជាឪពុកម្ដាយកុំព្យាយាមទិញការស្រឡាញ់និងការគោរពរបស់កូនៗនោះទេ។ គួរតែរកវិធីសាស្ត្រផ្សេងក្រៅពីលុយកាក់ និងរបស់របរ។ ដូចគ្នានេះផងដែរកុំព្យាយាមលុបលាងកំហុសរបស់អ្នកជាមួយនឹងប្រាក់ ឬក៏អំណោយ។ ជាការសំខាន់ដែលត្រូវសារភាពកុំហុសហើយសុំទោសពីព្រោះទង្វើរបស់អ្នក គឺវាខ្លាំងជាងពាក្យសម្ដីទៅទៀត។

**១១). ការនៅស្ងាត់ស្ងៀមដោយមិននិយាយនិងបញ្ចេញនូវសកម្មភាពអ្វី**

វាគឺជារឿងល្ងង់ខ្លៅដោយមិន"ដោះស្រាយ"បញ្ហាឬទំនាស់ដោយមិននិយាយស្ដីអ្វីទាំងអស់រឺបិទមាត់។ នៅក្នុងទំនាក់ទំនងណាក៏ដោយការប្រាស្រ័យទាក់ទងគ្នា គឺជាគន្លឹះ ហើយត្រូវតែនិយាយរឿងចេញមក។ **តទៅទំព័រទី ២២**




**ដំណឹងរកបុគ្គលិកចែកផ្សាយ**

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់មានឡូវែល - លីន រីវែរ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដងក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។

សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163**

ឬទាក់ទងមក **សូបិន 978-656 8141**

▸ វិធីសាស្ត្រដែលជួយសម្រកទំងន់ គឺការគ្រប់គ្រងរបបអាហាររបស់អ្នកឱ្យបានត្រឹមត្រូវ ។ តើគួរធ្វើដូចម្តេច ដើម្បីកុំឱ្យរាងកាយមានភាពទន់ខ្សោយ និងអាចគ្រប់គ្រងរបបអាហារបានទៀតនោះ ។ ខាងក្រោមគឺជាវិធីសាស្ត្រគ្រប់គ្រងរបបអាហារឱ្យបានត្រឹមត្រូវក្នុងខណៈពេលសម្រកទំងន់ :

-កាត់បន្ថយការទទួលទានបាយតាមប្រក្រតី គឺក្នុងការទទួលទានគួរកាត់បន្ថយឱ្យបានតិចជាងទំលាប់ប្រហែល ១ភាគ៣ ។

-ត្រូវទទួលទានសាច់ត្រី ស៊ុតពណិស តៅហ៊ូ និងផលិតផលពីសណ្តែកសៀង ជារៀងរាល់ថ្ងៃ ។

- គួរចៀសវាងការទទួលទានអាហារ ចៀន បំពង និងឆា គឺត្រូវផ្លាស់ប្តូរជ្រើសរើសយកអាហារដែលជាលក្ខណៈស្ងោរ ចំហុយ និងអាំងជំនួសវិញ ។

-ចៀសវាងទទួលទានចំណីអាហារដែលមានខ្លាញ់មានដូចជា ប្រេងដូង ប៊័រជាដើម ។ សូមទទួលទានប្រេងឆាធ្វើពីកន្ទក់ សណ្តែក សៀង និងប្រេងដែលធ្វើពីគ្រាប់ផ្កាឈូករ័ត្ន ។

-ពិសាភេសជ្ជៈទឹកដោះគោ ដែលគ្មានជាតិប៊័រ ក្នុងមួយថ្ងៃឱ្យបានពី១ទៅ២កែវ ។ បើពិសាទឹកដោះគោមិនបានត្រូវពិសាទឹកសណ្តែកជំនួស ។

-កាត់បន្ថយការពិសាទឹកស្ករ ឬស៊ីរ៉ូផ្អែម ទឹកក្រូច ទឹកផ្លែឈើ ដែលផ្អែមខ្លាំង ស្រា និងស្រាបៀរ ។

# អាថ៌កំបាំងគ្រប់គ្រងរបបអាហារ ដើម្បីសម្រកទំងន់



## តមកពីទំព័រទី ២១ អាកប្បកិរិយាទាំង...

អាកប្បកិរិយាបែបនេះ អាចបង្រៀនកូនៗអំពីវិធីមិនល្អក្នុងការប្រាស្រ័យទាក់ទងក្នុងសង្គម ។

**១២). ប្រងើយកណ្តើយចំពោះទង្វើជាគំរូ**

ប្រសិនបើឪពុកម្តាយចង់ឱ្យកូនគោរពមាតាបិតាក៏ត្រូវគោរពកូនផងដែរ ។ ឧទាហរណ៍ ប្រសិនបើឪពុកម្តាយមិនដែលធ្វើអ្វីទាន់ពេល តើអ្នកសង្ឃឹមថា កូនរបស់អ្នកនឹងទៅជាយ៉ាងណា?

**១៣). ឱ្យកូនមានការទទួលខុសត្រូវចំពោះ សុភមង្គលរបស់ខ្លួន**

ការក្លាយជាអាណាព្យាបាល គឺជាជំរើស និងការទទួលខុសត្រូវរបស់អ្នកឪពុកម្តាយមិនអាចរំពឹងទុកឱ្យកូនបំផ្លេចពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ហើយងាកមកមើលការខុសត្រូវ និងថែរក្សាឪពុកម្តាយតែមួយមុខនោះទេ ។ ឪពុកម្តាយមិនត្រូវធ្វើខ្លួនទៅជាបន្ទុករបស់កូននោះទេ ដោយសារកូននឹងមិនចង់ចំណាយពេលវេលាជាមួយអ្នកគ្រប់ពេលនោះទេ ។ មិនត្រូវបន្ទោសកូននៅពេលអ្នកមិនសប្បាយចិត្ត ។ ត្រូវចាំថា យើងម្នាក់ គឺទទួលខុសត្រូវសុភមង្គលរៀងៗខ្លួន ។

អាកប្បកិរិយាចំនួន១៣ខាងលើនេះ គួរតែឪពុកម្តាយជាសវាង ព្រោះវាប៉ះពាល់ដល់កូនៗរបស់អ្នក ។ មានវិធីជាច្រើននៃការចិញ្ចឹមកូន ដូច្នេះចូរធ្វើជាឪពុកម្តាយដ៏ល្អបំផុតដែលអ្នកអាចធ្វើបានមិនត្រឹមតែផ្តល់ឱ្យកូនរបស់អ្នកនូវជំរកមួយដែលមានសុវត្ថិភាព ក៏ត្រូវទុកពេលវេលាផ្ទាល់ខ្លួនគ្រប់គ្រាន់សម្រាប់កូនផងដែរ ។ ចូរនិយាយជាមួយកូនអំពីអ្វីៗដែលជាបញ្ហា និងអារម្មណ៍របស់ពួកគេ ប៉ុន្តែកុំមើលងាយពួកគេ ។ ឱ្យកូនធ្វើកំហុសហើយឱ្យពួកគេដឹងថាអ្នកនឹងនៅជាមួយពួកគេគ្រប់ពេលវេលាដើម្បីជួយគាំទ្រពួកគេ ៕




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- រឹកខឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

Red Rose
ភោជនីយដ្ឋាន RESTAURANT
កុលាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់
Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851
អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!
Mon-Sun
8am -8pm


បាយសាច់ជ្រូកពងទាចៀន


គុយទាវរួមមុខស្ស៊ី


មីកន្ធាំង


បបរគ្រឿង

* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់
(978) 452-5400



## តមកពីទំព័រទី ១៧ តំបន់មាត់ឃ្លាំងនៅក្នុងរដូវវស្សា...

មើលការខុសប្អូនស្រីច្រៀនកំពីស និងក្រូច លក់ ។ ក្នុង១សប្តាហ៍គាត់អាចរកចំណូលបាន ប្រមាណ៥០ម៉ឺនរៀល ។

ក្នុងរយៈពេល២ឆ្នាំមកហើយដែលទឹកទន្លេ មិនឡើងលិចត្រង់ទីតាំងមាត់ឃ្លាំង ដូច្នេះអ្នក ទេសចរជាតិ និងអន្តរជាតិមិនបានទៅកម្សាន្ត ទេនៅថ្ងៃចុងសប្តាហ៍ ។ ទើបតែឆ្នាំ២០១៧នេះ ទឹកទន្លេឡើងលិចមានអ្នកទេសចរច្រើនទៅ កម្សាន្ត ។ អ្នកនៅក្រុងកំពង់ចាម និងតាម មក គាត់លក់ដូរនៅក្បាលស្ពានមានផ្អកមុំ១ កំប៉ុងតូចតម្លៃ៤.០០០រៀល កំប៉ុងកណ្តាលតម្លៃ ១ម៉ឺនរៀល និងកំប៉ុងធំ១៥.០០០រៀល ។ ចាប់ តាំងពីលក់ជាង១០ឆ្នាំមកនេះ ក្នុង១ថ្ងៃអាចរក ចំណេញបានជាមធ្យម៣ម៉ឺនរៀល ។

លោក អឿន រិទ្ធិ ប្រធានមន្ទីរទេសចរណ៍ ខេត្តឱ្យដឹងថា នៅក្នុងឆ្នាំ ២០១៤ ស្ពានមាត់ឃ្លាំង ក្លាយជាកន្លែងទេសចរណ៍ ថ្មីក្នុងរដូវវស្សាដោយ ដាក់ឈ្មោះថា"ភូមិនេសាទ" ។ មន្ទីរបានណែនាំ





បណ្តាស្រុកផ្សេងៗទៀតទៅលេងជាហូរហែ ខ្លះជិះកង់ទឹកលេង និងទទួលទានអាហារនៅ តាមតូបលក់ដូរ ។

អ្នកស្រីមុត ចាន់ថន អាយុ៦០ឆ្នាំ រស់នៅ ភូមិទួលវិហារឱ្យដឹងថា ចាប់តាំងពីពេលដែល ស្ពានបេតុងមាត់ឃ្លាំងបើកសម្ពោធឱ្យប្រើប្រាស់ ដល់ក្រុមអាជីវករលក់ដូរត្រូវសំអាតអនាម័យ មិនត្រូវបោះសំរាមចោលទេ គឺត្រូវប្រមូលដាក់ ធុង ។ អាជីវករលក់ដូរមួយចំនួនធំបានអនុវត្តតាម ។ សព្វថ្ងៃនេះអ្នកខ្លះ នៅជិតស្ពានមាត់ឃ្លាំងចាក់ ដីពង្រីក និងត្រៀមសង់ប៉ម សម្រាប់អ្នកទេសចរ ជាតិថតទេសភាពព្រះអាទិត្យ ៕


# រកអ្នកធ្វើការ

ខ្មែរផុសស.រ.អា រកបុគ្គលិកចេះ
និយាយនឹងសរសេរភាសាខ្មែរច្បាស់លាស់
យល់ភាសាអង់គ្លេស
សម្រាប់ការងារជាអ្នកសរសេរព័ត៌មាន ។
សូមទូរស័ព្ទមកសូបិន **978-656 8141**



*For your special day...*
*សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក*



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL Inn & Conference Center

**សណ្ឋាគារយូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ**
ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាស យ៉ាងរំភើយ
លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយ មានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នក កំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើប សម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាង អាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់ បុគ្គលម្នាក់ៗបាន ។

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA

### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

Lowell
Lynn
Revere
Providence
Cranston

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

### *Khmer Post USA Distribution Locations Include:*

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2017 PRINTING DATES | 2018 PRINTING DATES |
|---|---|
| July 10 & 24 | January 5 & 19 |
| August 7 & 21 | February 5 & 19 |
| September 11 & 25 | March 5 & 19 |
| October 9 & 23 | April 6 & 20 |
| November 6 & 20 | May 7 & 21 |
| December 4 & 18 | June 8 & 2 |

***Advertising deadlines are 5 business days prior to printing date.***

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" x 6.5") | 165 | 940 | 1831 | 3,564 |
| **1/8** (5" x 3.25") | 90 | 513 | 999 | 1,944 |

### CONTACT INFO

45 Merrimack Street • Suite 218A • Lowell, MA 01852
Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us
www.khmerpost.us

CELEBRATING 10 YEARS

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*